# ជំពូក ៦

# ការប្រឹក្សា និង ពិគ្រោះយោបល់ ពីសាធារណជន

Public Consultation

Draft

# ជំពូកទី ៦

# ការប្រឹក្សាយោបល់ និង ពិគ្រោះយោបល់ពីសាធារណជន

## ៦.១ សេចក្តីផ្តើម

ការប្រឹក្សា និងពិគ្រោះយោបល់ពីសាធារណជនដែលពាក់ព័ន្ធដោយសារគំរោងនេះ គឺជាចំណុចមួយដ៏សំខាន់ដែល ធ្វើឡើងដើម្បីឱ្យសាធារណជនដែលពាក់ព័ន្ធទាំងនេះផ្តល់នូវមតិយោបល់ និងសំណូមពរក្នុងការជួយដល់ការអនុវត្តគំរោងឱ្យបានល្អប្រសើរ និងមានភាពរលូន ។

ការប្រឹក្សា និងពិគ្រោះយោបល់នេះ ដើម្បីបង្ហាញបន្ថែមនូវបញ្ហាប៉ះពាល់ ដែលកើតមានក្នុងដំណាក់កាលសាងសង់គំរោង ហើយបញ្ហាទាំងនេះ នឹងត្រូវយកមកវិភាគឱ្យបានពេញលេញ ក្នុងគោលបំណង ទាញយកផលមកវិញ ពីការបាត់បង់ធនធានដោយ សារគំរោង និងជួយទប់ស្កាត់ការបង្កគ្រោះមន្តរាយ ដែលអាចកើតមានដោយយថាហេតុណាមួយពីគំរោង នេះ ។

រយៈពេលការធ្វើការប្រឹក្សា និងពិគ្រោះយោបល់ពីអង្គភាព និងអាជ្ញាធរពាក់ព័ន្ធ ដោយសារគំរោងនេះ បានប្រព្រឹត្តទៅ ១០/០៣/២០១០ ដល់ ១៥/០៧/២០១០ ។

ការប្រឹក្សា និងពិគ្រោះយោបល់នេះ បានធ្វើការពិភាក្សាវែកញែក និងពន្យល់ឱ្យប្រជាពលរដ្ឋ នៅក្នុងតំបន់គំរោង ឱ្យបានយល់អំពីគោលបំណងនៃការអភិវឌ្ឍន៍គំរោង ដែលទៅថ្ងៃអនាគតនឹងនាំឱ្យពួកគាត់បានរីកចំរើន (ចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋក្នុងតំបន់គំរោង) ។

## ៦.២ គោលបំណងនៃការប្រឹក្សា

គោលបំណង នៃការប្រឹក្សា និងពិគ្រោះយោបល់ពីសាធារណជន មានគោលបំណងដូចតទៅ :

- ស្វែងរកមតិរិះគន់ សំណូមពរ បញ្ហាទំនាស់ និងរកវិធីសាស្ត្រកែលំអផ្សេងៗ ដើម្បីឱ្យគំរោងនេះទទួលបានជោគជ័យ ។
- រកវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាននៃគំរោងវារីអគ្គិសនីកំចាយនេះឱ្យកាន់តែមានប្រសិទ្ធភាព ។

## ៦.៣ លទ្ធផល នៃការប្រឹក្សា និងពិគ្រោះយោបល់ពីសាធារណជន

ក្រុមការងារសិក្សាស្រាវជ្រាវផ្នែកការវាយតំលៃហេតុប៉ះពាល់បរិស្ថានសង្គមរបស់ SAWAC បានធ្វើការប្រឹក្សា និងពិគ្រោះយោបល់ ពីអាជ្ញាធរពាក់ព័ន្ធ និងអង្គភាពពាក់ព័ន្ធ ដូចខាងក្រោម:

- អភិបាលរងខេត្តកំពត និងប្រធានមន្ទីរបរិស្ថាន ខេត្តកំពត
- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពត
- អភិបាលរងស្រុកទឹកឈូ និងមេឃុំម៉ាក់ប្រាង្គ
- ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកំពត
- ប្រធានរដ្ឋករទឹក ខេត្តកំពត
- ប្រធានអគ្គិសនី ខេត្តកំពត
- ប្រធានមន្ទីរធនធានទឹក និង ឧតុនិយម ខេត្តកំពត





Draft

- នាយខ័ណ្ឌរដ្ឋបាលព្រៃឈើ ខេត្តកំពត
- នាយរងខ័ណ្ឌរដ្ឋបាលជលផល ខេត្តកំពត
- ប្រធានឧទ្យានជាតិព្រះមុនីវង្ស បូកគោ
- និងប្រជាពលរដ្ឋ ដែលត្រូវប៉ះពាល់ជាមួយគំរោង ។

លទ្ធផលនៃការប្រឹក្សាយោបល់ខាងលើ មានលំអិតតាមលំដាប់ថ្នាក់នានុក្រម ដូចខាងក្រោម :

### ៦.៣.១ លទ្ធផល នៃការប្រជុំប្រឹក្សាយោបល់របស់ក្រុមការងារជាមួយអភិបាលរងខេត្តកំពត និងប្រធានមន្ទីរបរិស្ថាន ខេត្តកំពត

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ របស់ក្រុមការងារ SAWAC ជាមួយលោក **ហេង ចន្ថា** អភិបាលរង ខេត្តកំពត និងលោក **ស៊ុយ ឆា** ប្រធានមន្ទីរបរិស្ថាន ខេត្តកំពត បានប្រព្រឹត្តិទៅនៅថ្ងៃទី១១ ខែមិនា ឆ្នាំ២០១០ វេលាម៉ោង ៨:០០ នាទី ដល់ម៉ោង ០៩:៣០នាទី ព្រឹក នៅមន្ទីរបរិស្ថាន ខេត្តកំពត បានទទួលលទ្ធផល ដូចខាងក្រោម :

មតិអភិបាលរង :

- គំរោងនេះ ពុំមានការប៉ះពាល់បរិស្ថានសង្គម ដោយសារការជំលៀសប្រជាពលរដ្ឋចេញតំបន់លិចទឹក (អាងស្តុកទឹក) នោះទេ ព្រោះថាក្នុងតំបន់លិចទឹករបស់គំរោង ពុំមានអ្នកស្រុករស់នៅនោះទេ ។ រីឯការប៉ះពាល់ដីប្រើប្រាស់ របស់ប្រជាពលរដ្ឋ ដោយសារការកសាងផ្លូវសំរាប់ដឹកថ្ម ដើម្បីធ្វើការសាងសង់ហេដ្ឋារចនាគំរោង ឃើញថា ក្រសួង និងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ព្រមទាំងគណៈកម្មការខេត្ត បានដោះស្រាយជាមួយក្រុមហ៊ុន ជូនប្រជាពលរដ្ឋ ដែលប៉ះពាល់ទាំងនោះ បានរួចរាល់ហើយដែរ ។
- ហេតុប៉ះពាល់អវិជ្ជមានដល់ធនធានធម្មជាតិ និងបញ្ហាប៉ះពាល់អវិជ្ជមានដល់បញ្ហាសេដ្ឋកិច្ចសង្គម គិតថាវាជាគោលដៅសំខាន់ក្នុងការសិក្សា របស់ក្រុមការងារសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន នេះ ។
- ក្តីសង្ឃឹមរបស់គំរោងនេះ វាជាផលប្រយោជន៍រួមសំរាប់ការអភិវឌ្ឍគ្រប់វិស័យ និងផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋគ្រប់រូបផងដែរ ។
- គំរោងនេះ បានផ្តល់ការងារធ្វើដល់ប្រជាពលរដ្ឋមូលដ្ឋាន សំរាប់ដោះស្រាយជីវភាពប្រចាំថ្ងៃរបស់គាត់ ជាពិសេសប្រជាពលរដ្ឋនៅស្រុកទឹកឈូទាំងមូល ។
- ចំពោះព្រៃឈើ ដែលត្រូវសំអាតចោលទាំងស្រុងក្នុងតំបន់អាង គួរតែរៀបចំធ្វើសារពើភ័ណ្ឌឱ្យបានឆាប់រហ័ស ព្រោះ ថា រដូវវស្សាជិតមកដល់ហើយ ។
- ក្រុមការងារ SAWAC គួរកំណត់បរិមាណព្រៃឈើ ដែលត្រូវសំអាតក្នុងអាង ឱ្យបានឆាប់រហ័ស មុនរដូវវស្សានេះ ពីព្រោះខណ្ឌរដ្ឋបាលព្រៃឈើ ហាក់បីដូចជាមានការយឺតយ៉ាវណាស់ លើការងារកំណត់បរិមាណព្រៃឈើនេះ មិនដឹង ហេតុអ្វីនោះទេ ។
- គួរពិភាក្សាផ្អាកពីបញ្ហាការថែរក្សាព្រៃជុំវិញតំបន់គំរោង ដើម្បីធ្វើឱ្យតំបន់គំរោងមានព្រៃឈើ អាចស្រូបយកទឹកភ្លៀង ផ្គត់ផ្គង់ដល់ដំណើរការគំរោងបានយូរអង្វែង ។

មតិលោកប្រធានមន្ទីរបរិស្ថាន :

Draft

- ការបំផ្លាញព្រៃឈើ និងធ្វើឱ្យមានការខ្វះខាតប្រភពទឹកសំរាប់គំរោង បើសិនជាក្រុមហ៊ុនមិនមានមូលនិធិសំរាប់គ្រប់គ្រងការពារ និងអភិរក្សព្រៃឈើ នៅជុំវិញតំបន់គំរោងនោះទេ ។
- ក្រុមហ៊ុនវិនិយោគគួរតែកំណត់ទំហំព្រៃដែលបាត់បង់ឱ្យបានច្បាស់លាស់ ក្នុងអាងរបស់គំរោង ដើម្បីរាជរដ្ឋាភិបាលអាចធ្វើការប៉ាន់ប្រមាណ តំលៃសំរាប់ចំណូលថវិកាជាតិ ។
- ក្រុមហ៊ុនវិនិយោគ គួរតែសហប្រតិបត្តិការជាមួយរដ្ឋអំណាចភូមិ-ឃុំ ពាក់ព័ន្ធដើម្បីជ្រើសរើស ប្រជាពលរដ្ឋ ទាំងស្រី ទាំង ប្រុស ធ្វើជាកម្មកររបស់គំរោង ។
- ក្រុមហ៊ុនត្រូវសាងសង់សំណង់ហេដ្ឋារចនាសម្ព័ន្ធគំរោង និងផ្លូវទៅតំបន់គំរោងទៅតាមបទដ្ឋានបច្ចេកទេសត្រឹមត្រូវដើម្បីធានាគុណភាព និងសុវត្ថិភាព ។
- គួរធ្វើជើងទេរជាថ្នាក់ៗ ដើម្បីការពារការហូរច្រោះដី និងបាក់ថ្ម ជៀសវាងបង្កគ្រោះថ្នាក់ច្រើនយ៉ាងក្នុងតំបន់គំរោង និងផ្នែកខាងក្រោមតំបន់គំរោង ។
- ក្រុមហ៊ុនគួរសហការជាមួយក្រុមហ៊ុនដឹកសំរាមរបស់ខេត្ត ក្នុងការចោលសំរាម ។
- ក្រុមហ៊ុនត្រូវសាងសង់កន្លែងស្នាក់នៅរបស់បុគ្គលិក-កម្មករគំរោង ក្នុងដំណាក់កាលសាងសង់គំរោង ឱ្យមានអនាម័យល្អ ដូចជាមានកន្លែងដាក់សំរាម បង្គន់អនាម័យ ។ល ។
- ក្រុមហ៊ុនត្រូវសំអាតទឹកកខ្វក់ចេញពីបង្គន់ បន្ទប់ទឹក ផ្ទះបាយមុនបង្ហូរទឹកកខ្វក់នេះមកផ្នែកខាងក្រោមតំបន់ គំរោង ។
- គួរឱ្យមន្ត្រីមន្ទីរបរិស្ថាន ចូលរួមជាមួយក្រុមការងារ SAWAC ក្នុងការងារវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម លើគំរោងវារីអគ្គិសនីកំចាយ ដើម្បីធ្វើឱ្យមន្ត្រីបរិស្ថានទាំផ្លូវ និងមានការយល់ដឹងបន្ថែមទៀតអំពីការងារនេះ ។

**<u>សំណូមពរ</u>** : សូមឱ្យក្រុមហ៊ុនវិនិយោគ ឧបត្ថម្ភដល់មន្ត្រីបរិស្ថានខេត្ត ចំនួន ៥-១០នាក់ ក្នុងការល្បាត ការពារព្រៃឈើជុំវិញតំបន់គំរោង ។

### ៦.៣.២ លទ្ធផល នៃការប្រជុំប្រឹក្សាយោបល់ជាមួយក្រុមការងារជាមួយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពត

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ របស់ក្រុមការងារ SAWAC ជាមួយ **ឆាំង ប៊ុណ្ណារ័ត្ន** ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពត បានប្រព្រឹត្តិទៅនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០ វេលាម៉ោង ១០:៣០ នាទី ដល់ម៉ោង ១១:៣០នាទី បានទទួលលទ្ធផល ដូចខាងក្រោម :

- គំរោងនេះ មានផលប៉ះពាល់លើដីប្រើប្រាស់របស់ប្រជាពលរដ្ឋ ដែលឋិតក្នុងតំបន់ឧទ្យានជាតិព្រះមនីវង្សបូកគោ និងគ្មានប័ណ្ណសំគាល់កម្ម សិទ្ធ ហើយក្រុមហ៊ុនបានសងសំណងអាស្រ័យផលជាការត្រឹមត្រូវហើយ ។ តែចំពោះដីងមួយចំនួន មានប័ណ្ណចេញមុនឆ្នាំ១៩៩២ តែមិនដឹងចំនួនប៉ុន្មាននោះទេ ប្រភេទដីនេះគួរដោះស្រាយសងទាំងថ្លៃដី និងសងថ្លៃដំណាំផងដែរ ។

- បើប្រជាពលរដ្ឋមកកាន់កាប់ក្រោយឆ្នាំ១៩៩២ក្នុងតំបន់គំរោង ឬក្បែរតំបន់គំរោង ដែលជាដីរបស់ឧទ្យានជាតិវាជាការខុសច្បាប់ អាចដកហូតបាន ។
- ចំពោះដីក្នុងតំបន់ក្បែរគំរោង មន្ទីរអាចចេញប័ណ្ណសំគាល់កម្មសិទ្ធឱ្យបាន លុះត្រាឧទ្យានជាតិព្រះមនីវង្សបូកគោរាយការណ៍ថា ដីនេះមិនប៉ះពាល់ដីរបស់ឧទ្យានជាតិ ទេ និងមានការពិនត្យជាក់ស្តែងបន្ថែមទៀត ។
- ពុំមានស្ថិតិប្រជាពលរដ្ឋ ដែលបានរស់នៅក្នុងតំបន់គំរោងនេះទេ ។

**សំណូមពរ :**

- សូមឱ្យក្រុមហ៊ុនមានការសហការល្អជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពតឱ្យបាន ល្អប្រសើរ ។
- សូមឱ្យក្រុមការងារសិក្សាផលប៉ះពាល់បរិស្ថាន សិក្សាលំអិតបន្ថែមទៀត និងមានការចូលរួមផ្តល់យោបល់ច្រើនកាន់ តែល្អ ជាពិសេស ប្រជាពលរដ្ឋ អាជ្ញាធរមូលដ្ឋាន អង្គភាព ស្ថាប័ន ក្រសួង និងអង្គការពាក់ព័ន្ធនានា ។
- សូមឱ្យក្រុមហ៊ុនវិនិយោគនេះ មានទំនាក់ទំនងល្អ ជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ដើម្បីរួមគ្នាដោះស្រាយ នូវបញ្ហាអសកម្មមួយចំនួន ដែលនឹងកើតមានឡើងជាពិសេសក្នុងពេលសាងសង់គំរោងនេះ ។
- សូមឱ្យក្រុមហ៊ុន សាងសង់រាល់ហេដ្ឋារចនាសម្ព័ន្ធ ដោយផ្អែកទៅបទដ្ឋានបច្ចេកទេស និងកំណត់ឱ្យច្បាស់នូវគុណភាព និងសុវត្ថិភាព ដើម្បីជៀសវាងគ្រោះថ្នាក់ជាជាយថាហេតុ ។
- សូមឱ្យមានការជួសជុលហេដ្ឋារចនាសម្ព័ន្ធគំរោងឱ្យបានរឹងមាំឡើងវិញ មុនពេលប្រគល់គំរោងនេះទៅឱ្យរាជរដ្ឋាភិបាលកម្ពុជាគ្រប់គ្រងបន្ត ។

### ៦.៣.៣ លទ្ធផលនៃការប្រជុំប្រឹក្សាយោបល់របស់ក្រុមការងារជាមួយអភិបាលរងស្រុកទឹកឈូ និងមេឃុំម៉ាក់ប្រាង

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់របស់ក្រុមការងារ SAWAC ជាមួយលោកស្រី **ម៉េង សុធា** អភិបាលរងស្រុកទឹកឈូ និងលោក **សេង រាយ** មេឃុំម៉ាក់ប្រាង បានប្រព្រឹត្តិទៅនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ វេលាម៉ោង០៨:៣០នាទី ដល់ម៉ោង ០៩:៣០នាទី ព្រឹក បានទទួលលទ្ធផល ដូចខាងក្រោម :

- សូមគាំទ្រគំរោងនេះ ១០០ភាគរយ ដោយសារ តម្រូវការថាមពលអគ្គិសនីសំរាប់ការអភិវឌ្ឍន៍ប្រទេសជាតិ គឺមានសារៈសំខាន់ណាស់ ។ ទោះបីជាមានការប៉ះពាល់ដីប្រជាពលរដ្ឋពិតមែន តែរដ្ឋាភិបាលបានតំរូវឱ្យក្រុមហ៊ុន ចេញសំណង ទូទាត់ តាមកិច្ចព្រមព្រៀងរួចរាល់ហើយ ដោយគ្មានទំនាស់អ្វីទេ ។
- ការដឹកជញ្ជូនរបស់ក្រុមហ៊ុនបានធ្វើឱ្យប៉ះពាល់ដល់ការរស់នៅផងដែរ តែអាជ្ញាធរស្រុកទឹកឈូបានធ្វើសំណើទៅអន្លីរឧស្សាហកម្មឱ្យជួយដោះស្រាយរឿងនេះ ដើម្បីធ្វើយ៉ាងណាឱ្យក្រុមហ៊ុនស្រោចទឹកផ្លូវជាប្រចាំ ជាពិសេសនៅទីប្រជុំជននិមួយៗ ជៀសវាងការហុយធូលីដីនិងកំទេចថ្មធ្វើឱ្យប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ ។ សំណើនេះយើងឃើញក្រុមហ៊ុនបានអនុវត្តន៍ តែមិនបានតាមសំណូមពរ នោះទេ ឃើញធ្វើនៅពេលណាមានការត្រួតពិនិត្យម្តងម្កាលប៉ុណ្ណោះ ។

- ក្រុមហ៊ុនបានធ្វើផ្លូវសំរាប់ដឹកថ្មទៅតំបន់គំរោង តែនៅកន្លែងផ្លូវទឹក ឬអូរមិនបានដាក់លូរ ឬស្ពាននោះទេ ជាហេតុធ្វើឱ្យមានការលិចលុងក្នុងរយៈពេលយូរ សំរាប់ភូមិនៅប៉ែកខាងលើ នឹងធ្វើឱ្យខូចខាតផ្ទះសម្បែង និងផលដំណាំ ឬជីវិតមនុស្ស-សត្វ នៅពេលមានទឹកជំនន់កើតឡើង។
- ក្នុងកំឡុងពេលកំពុងសាងសង់នេះ ប្រជាពលរដ្ឋមួយចំនួនមិនហូបទឹកស្អាតរបស់ខេត្តទេ ព្រោះក្លាចមានជំងឺ ដោយសារ ទឹកព្រែកមានជាតិស៊ីម៉ង់ត៍ច្រើនពេក។
- សព្វថ្ងៃមានការសំអាតព្រៃ ក្នុងអាងវារីអគ្គិសនី ក្នុងតំលៃ២០០ដុល្លារ/ហិកតា តែមិនដឹងថាមានបង្កើតគណៈកម្មការ របស់រដ្ឋាភិបាលត្រួតពិនិត្យការសំអាតឈើនេះដែរឬទេ?
- ចំពោះឈើក្នុងអាង ជាឈើមិនមានតំលៃសេដ្ឋកិច្ចខ្ពស់នោះទេ ហើយឈើខ្លះខូចគុណភាព ទៀតផង។
- រីឯអ្នកប្រកបរបរ ខាងទេសចរ នៅតំបន់ទឹកឈូ មានចំណូលថយចុះ បើធៀបទៅនឹងមុនដំណាក់កាលសាងសង់ វារីអគ្គិសនីប្រមាណ ៥០-៨០ភាគរយ ដោយសារ បញ្ហាទឹកឈូនេះ មានជាតិស៊ីម៉ង់ត៍ច្រើន មានកាកសំណល់កខ្វក់ ពីបង្គន់ ផ្ទះបាយ និងពីបន្ទប់ទឹក មិនអាចងូតទឹកកំសាន្តបាន។
- ប្រជាពលរដ្ឋបានឃើញត្រីមួយចំនួនងាប់ អណ្តែតតាមព្រែកកំចាយ ផងដែរ តែមិនទាន់មានមូលហេតុច្បាស់លាស់។
- ឆ្នាំ២០១០នេះ មានការរាំងស្ងួត និងការថយចុះចំនួនទេសចរនេះ បានធ្វើឱ្យប្រជាពលរដ្ឋ នៅខេត្តកំពត ជួបបញ្ហាខ្វះខាត ជីវភាពជាងបណ្តាឆ្នាំកន្លងទៅ។

**<u>សំណូមពរ</u> :**

- សូមឱ្យក្រុមហ៊ុន មានការសហការល្អជាមួយអាជ្ញាធរមូលដ្ឋាន ជាពិសេស ជាមួយអាជ្ញាធរឃុំពាក់ព័ន្ធ។
- សូមឱ្យក្រុមការងារសិក្សា វាយតំលៃហេតុប៉ះពាល់បរិស្ថាន គំរោងវារីអគ្គិសនីកំចាយនេះ កត់ត្រានូវបញ្ហាខាងលើ និង រកដំណោះស្រាយសមស្រប ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋ។

### ៦.៣.៤ លទ្ធផល នៃការប្រជុំប្រឹក្សាយោបល់ជាមួយប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពត

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ របស់ក្រុមការងារ SAWAC ជាមួយលោក **សោម វិចិត្រ** ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពត បានប្រព្រឹត្តិទៅនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ វេលាម៉ោង ១០:២០ នាទី ដល់ម៉ោង ១១:២០នាទី ព្រឹក បានទទួលលទ្ធផលដូចខាងក្រោម :

- ខេត្តកំពតមានបង្កើតគណៈកម្មការដោះស្រាយទំនាស់ ជាមួយក្រុមហ៊ុន Sinohydro ដែលក្នុងនោះ មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ជាអ្នកសំរបសំរួល រាល់កិច្ចការពាក់ព័ន្ធ ។
- សព្វថ្ងៃមន្ទីរ កំពុងមានការសិក្សាលើគំរោងផ្គត់ផ្គង់ទឹកស្អាត សំរាប់ខេត្តកំពត ដែលនឹងប្រើបំពង់បង្ហូរទឹក ពីទំនប់វារីអគ្គិសនីកំចាយ តាមប្រសាសន៍របស់សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន ហើយ។
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ហាមមិនឱ្យប្រកាសនូវតួរលេខនៃកំលាំងថាមពលអគ្គិសនី ដែលគំរោងវារីអគ្គិសនីមានការប្រែប្រួលបន្តិចបន្តួចនោះទេ គឺត្រូវប្រើតួរលេខរបស់ក្រសួង ដែលបានឆ្លងសភារួចហើយតែប៉ុណ្ណោះ

- ពាក់ព័ន្ធនឹងការដោះស្រាយផលប៉ះពាល់ទាំងឡាយ គឺមិនមែនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកសំរបសំរួល និងដោះស្រាយនោះទេ គឺនេះជាការវិនិយោគក្រោមសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដូចនេះ ការសំរបសំរួល ផលប៉ះពាល់ទាំងឡាយ វាជានិតិវិធីរបស់ក្រសួង និងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពត ។ ជាក់ស្តែងការប៉ះពាល់ដីប្រើប្រាស់របស់ប្រជាពលរដ្ឋ ភាគច្រើនដោះស្រាយសំណងអាស្រ័យផល : ចំពោះការប៉ះពាល់លើចំការធូរេន គឺគោលការណ៍របស់ក្រុមហ៊ុនសង ក្នុង១ដើម សង៥០០ដុល្លារអាមេរិក ធូរេនអត់ផ្លែ ១ដើម សង២០០ដុល្លារអាមេរិក ក្រៅពីដើមធូរេន គឺ១ដើម សង១០០ដុល្លារអាមេរិក ។
- តាមការពិនិត្យលើសកម្មភាពសាងសង់របស់ក្រុមហ៊ុន មន្ទីរអាចសន្និដ្ឋានថា គំរោងសាងសង់នឹងរួចរាល់មុនផែនការ ។ ឥឡូវនេះសំរេចបានប្រមាណ ៥០ភាគរយ ហើយ ។
- ក្រុមហ៊ុននេះ មានការគោរពលើអ្វីដែលគណៈកម្មការដោះស្រាយទំនាស់ ខេត្តកំពត បានដាក់ជូន ដូចជា ការតំរូវឱ្យក្រុមហ៊ុនសាងសង់ផ្លូវ រ៉បតាមផ្លូវជាតិលេខ៣ ចំងាយ១៤ គ.ម សំរាប់ក្រុមហ៊ុនដឹកថ្ម ពីតំបន់ភ្នំល្អាង ជៀសវាងខូចខាត ផ្លូវលេខ៣ ដែលកំពុងសាងសង់ដែរនោះ គឺក្រុមហ៊ុនអនុវត្តន៍តាមគោលការណ៍នេះ ។ ចំពោះសំណងលើការប៉ះពាល់ដំណាំ ប្រជាពលរដ្ឋ ក្នុងការធ្វើផ្លូវដឹកថ្មពីផ្លូវជាតិលេខ៣ ទៅការដ្ឋានរបស់គំរោង គឺក្រុមហ៊ុនជាអ្នកសងដោយផ្ទាល់ ក្រោយពីទទួលបានគោលការណ៍របស់គណៈកម្មការខេត្តកំពតរួចមក ។
- ចំពោះផលប៉ះពាល់បរិស្ថានក្នុងបរិយាកាស ដូចជាការដឹកដី ថ្ម នៅទីប្រជុំជន សាលារៀន ។ល ។ គឺក្រុមហ៊ុនបានជួលប្រជាពលរដ្ឋ រ៉ែកទឹកស្រោចមិនឱ្យហុយធូលីដី ថ្ម ឡើយ ។ ជាក់ស្តែង នៅមុខសាលារៀនមួយក្បែរតំបន់គំរោង ដែលជាប់ជាមួយផ្លូវ ដឹកថ្ម គឺក្រុមហ៊ុនបានជួលប្រជាពលរដ្ឋ៤-៥នាក់ រ៉ែកទឹកស្រោចជាប្រចាំ ។
- អន្តរក្រសួងកំពុងមានការសិក្សា ការបញ្ចូលប្រព័ន្ធខ្សែបញ្ជូនចរន្តចំរុះ ពីខេត្តព្រះសីហនុ មកខេត្តកំពត និងពីខេត្តកំពត ទៅរាជធានីភ្នំពេញ ។

**<u>សំណូមពរ :</u>**

- សូមឱ្យក្រុមហ៊ុនជួយលើការងារបណ្តុះបណ្តាលមន្ត្រីជំនាញ ផ្នែកគ្រប់គ្រងប្រព័ន្ធវារីអគ្គីសនី និងវិស្វកម្មសំណង់ វារីអគ្គិសនីនេះផង ដើម្បីធ្វើឱ្យប្រទេសកម្ពុជាយើង មានធនធានមនុស្សលើផ្នែកនេះពិតប្រាកដ ហើយនឹងអាចបន្តវេនពីក្រុមហ៊ុន នៅពេលក្រុមហ៊ុនបញ្ចប់អាណត្តិ ។
- សូមក្រុមហ៊ុនវិនិយោគវារីអគ្គិសនីនេះផ្តល់ឱ្យមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល នូវឯកសារភូគព្ភសាស្ត្រ និងរ៉ែ ដែលបានសិក្សា នៅតំបន់គំរោងនេះផង ។
- សូមឱ្យក្រុមហ៊ុនត្រៀមថវិកាសំរាប់គណៈកម្មការជាតិក្នុងការត្រួតពិនិត្យ និងគ្រប់គ្រងក្នុងដំណើរការប្រតិបត្តិ និងថែទាំ របស់គំរោង ។

៦.៣.៥ លទ្ធផល នៃការប្រជុំប្រឹក្សាយោបល់របស់ក្រុមការងារជាមួយប្រធានរដ្ឋាករទឹក ខេត្តកំពត

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ របស់ក្រុមការងារ SAWAC ជាមួយលោក **ប៊ុន ចាន់ពង់** ប្រធានរដ្ឋករទឹក ខេត្តកំពត និងលោក **វង្ស សាម៉ុន** អនុប្រធានរដ្ឋករទឹក ខេត្តកំពត បានប្រព្រឹត្តិទៅនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០ វេលាម៉ោង ០៨:៣០ នាទី ដល់ម៉ោង ១០:០០នាទី ព្រឹក បានទទួលលទ្ធផលដូចខាងក្រោម :

Draft

- សូមគាំទ្រទាំងស្រុងលើគំរោងវារីអគ្គិសនីកំចាយនេះ និងសប្បាយរីករាយ ដោយសង្ឃឹមថាក្រុមហ៊ុននឹងសំរួលដាក់បំពង់បង្ហូរទឹក ដល់ស្ថានីយទឹកស្អាតខេត្តកំពត តាមអនុសាសន៍របស់សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន ក្នុងពិធីចុចប៊ូតុងឱ្យដំណើរការវារីអគ្គិសនីទី២ កំចាយ ដូចមានប្រសាសន៍ថា" ការបង្ហូរទឹកពីទំនប់វារីអគ្គិសនីតែម្តងដោយមិនបាច់បូមបញ្ជូនមកខេត្តកំពត ទៀតទេ" ។
- ការពិភាក្សាថ្ងៃនេះ យើងគួរចាប់អារម្មណ៍ ការតបំពង់ទឹកពីទំនប់វារីអគ្គិសនីនេះ និងធ្វើយ៉ាងណាឱ្យមានដំណើរការល្អប្រសើរ ។
- ការពិភាក្សានេះបានឯកភាពគ្នាថា គួរសិក្សា និងធ្វើផែនការសាងសង់ស្ថានីយទឹកស្អាតថ្មី ហើយរៀបចំដាក់បំពង់ទឹក ពីទំនប់វារីអគ្គិសនីចេញឱ្យផុតពីបរិវេណរបស់គំរោង បន្តិច ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង របស់រដ្ឋាករទឹកខេត្តកំពត ។
- នៅរដូវប្រាំង អាចមានការខ្វះខាតប្រភពទឹកផ្គត់ផ្គង់ទួរប៊ីន ដើម្បីផលិតថាមពលអគ្គិសនី ធ្វើឱ្យក្រុមហ៊ុនបិទមិនបង្ហូរទឹកតាមបំពង់ផ្តល់ឱ្យស្ថានីយថ្មី នោះខេត្តនឹងត្រូវគ្មានទឹកប្រើប្រាស់ដូចមុនទៀតទេ ដូចនេះ ស្ថានីយទឹកស្អាតចាស់គឺ យើងត្រូវរក្សាទុកដដែល ដើម្បីបូម និងសំអាតទឹកសំរាប់ប្រើប្រាស់ទូទាំងខេត្ត ឱ្យមាននិរន្តរភាពរហូត ។
- បំពង់បង្ហូរទឹកគួរជ្រើសយកទំហំ ៥០០ម.ម ដើម្បីធ្វើឱ្យបរិមាណទឹកអាចផ្គត់ផ្គង់ដល់ខេត្តកំពត សំរាប់ឆ្នាំ២០២០ ប្រមាណ ៣០០ម³/ម៉ោង ។
- គួរសិក្សាកំរិតកំពស់ទឹកនៅទំនប់ទី១ ទំនប់ទី២ ជាមុនសិន ដើម្បីកំណត់ទីតាំងដាក់បំពង់បង្ហូរទឹកមកអនុស្ថានីយថ្មី ។

**សំណូមពរ :**

សូមឱ្យក្រុមការងារ SAWAC ជួយសិក្សា ឬស្វែងរកទិន្នន័យកំរិតកំពស់ទឹក ពីក្រុមហ៊ុនវិនិយោគគំរោងវារីអគ្គិសនីកំចាយ ដើម្បីធ្វើឱ្យរដ្ឋករទឹកខេត្តកំពតមានលទ្ធភាពសិក្សាទីតាំងដាក់បំពង់បង្ហូរទឹក និងធ្វើគំរោងសាងសង់អនុស្ថានីយទឹកស្អាតថ្មី ដោយមិន បាច់ប្រើម៉ាស៊ីនបូមទឹកពីព្រែក ដូចសព្វថ្ងៃ ។

### ៦.៣.៦ លទ្ធផល នៃការប្រជុំប្រឹក្សាយោបល់ខោចក្រុមការងារជាមួយប្រធានអគ្គិសនី ខេត្តកំពត

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់របស់ក្រុមការងារ SAWAC ជាមួយលោក **ឈឹម សឿង** ប្រធានអគ្គិសនីខេត្តកំពត បានប្រព្រឹត្តិទៅនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ វេលាម៉ោង០៤:៣០នាទី ដល់ម៉ោង ០៥:៣០នាទី ល្ងាច បានទទួលលទ្ធផលដូចខាងក្រោម :

- សូមគាំទ្រទាំងស្រុងនូវការអភិវឌ្ឍន៍គំរោងវារីអគ្គិសនីនេះ ដោយហេតុថា វាជាតំរូវការចាំបាច់សំរាប់ប្រទេសជាតិ សំរាប់អភិវឌ្ឍន៍ប្រទេសជាតិគ្រប់វិស័យ ជាពិសេស ខេត្តកំពត នឹងមានផែនការអភិវឌ្ឍន៍ជាច្រើនដែលសុទ្ធសឹងពឹងផ្អែកទៅលើថាមពលអគ្គិសនីនេះ ។
- ការរៀបចំដាក់ខ្សែបញ្ជូនចរន្តអគ្គិសនី បើតាមផែនការរបស់ក្រុមហ៊ុនប្រហែលជារត់តាមផ្លូវក្បែរចំការធូរេន ។ បើដូច្នេះមែនក្រុមហ៊ុននឹងត្រូវចំណាយលើការសងផលដំណាំ និងដីប្រើប្រាស់របស់ប្រជាពលរដ្ឋមួយចំនួនទៀត ។ តែបើខ្សែបញ្ជូនរត់រប តាមផ្លូវរត់ភ្លើងវិញ វានឹងមានផលប៉ះពាល់តិចតួចជាង ។



Draft

- ការបារម្ភវិញ គឺការខ្វះខាតទឹកនៅរដូវប្រាំង សំរាប់ផ្គត់ផ្គង់ដំណើរការវារីអគ្គិសនី ។ សព្វថ្ងៃស្ថានីយអគ្គិសនីទី២នៃគំរោងនេះ ដែលអាចផលិតអគ្គិសនីបានកំលាំង ១០,១ MW បានសាងសង់រួចរាល់ហើយ តែពុំមានប្រភពទឹកក្នុងរដូវប្រាំងនេះ ដូចនេះ វាក៏មិនអាចផលិតថាមពលអគ្គិសនីបានដែរ ។
- តំលៃលក់របស់ក្រុមហ៊ុន ឱ្យទៅ EDC តំលៃ៨សេន ក្នុង១គ.វ៉ ក្នុងដំណាក់កាលដំបូង ដូចនេះ តំលៃអគ្គិសនីអាចលើសពីនេះ ដោយសារ យើងត្រូវការអ្នកវិនិយោគបណ្តាញចែកចាយអគ្គិសនី បន្ថែមទៀត ។

<u>សំណូមពរ</u> :

សូមឱ្យក្រុមហ៊ុន ជួយថែរក្សាព្រៃឈើ នៅជុំវិញតំបន់គំរោង កុំបាត់បង់ បើមិនដូច្នេះទេ ច្បាស់ជាខ្វះប្រភពទឹកសំរាប់ ដំណើរការផលិតថាមពលវារីអគ្គិសនីនេះហើយ ។

### ៦.៣.៧ លទ្ធផល នៃការប្រជុំប្រឹក្សាយោបល់របស់ក្រុមការងារជាមួយប្រធានមន្ទីរធនធានទឹក និង ឧតុនិយម ខេត្តកំពត

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់របស់ក្រុមការងារ SAWAC ជាមួយលោក **ចាន់ វណ្ណា** ប្រធានមន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពត និងលោក **វិន សូត្រ** ប្រធានការិយាល័យរដ្ឋបាល នៃមន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពត បានប្រព្រឹត្តិទៅ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ វេលាម៉ោង០៦:០០នាទី ដល់ម៉ោង ០៧:០០នាទី ល្ងាច បានទទួលលទ្ធផលដូចខាងក្រោម :

- គំរោងវារីអគ្គិសនីនេះ សាងសង់ឡើង ដោយពុំមានឆ្លងកាត់ការផ្តល់យោបល់អ្នកជំនាញឱ្យបានគ្រប់គ្រាន់នោះទេ ជាពិសេស យោបល់របស់ជំនាញថ្នាក់ខេត្ត ។
- ការសាងសង់នេះហាក់ដូចពុំមានទំនប់បំរុង សំរាប់ការពារបរិមាណទឹក ក្នុងករណីបាក់ទំនប់ទី១ នៅពេលមានទឹ ជំនន់ធំៗ កើតឡើង នៅរដូវវស្សា ។
- គួរមានការព្រួយបារម្ភផងដែរ អំពីគុណភាពសំណង់ នេះ ។

<u>សំណូមពរ</u> :

សូមឱ្យក្រុមការងារ ជួយពិនិត្យមើល និងវាយតំលៃហេតុប៉ះពាល់ឱ្យបានល្អិតល្អន់ បន្តិចលើការងារសាងសង់នេះ ។

### ៦.៣.៨ លទ្ធផល នៃការប្រជុំប្រឹក្សាយោបល់របស់ក្រុមការងារជាមួយនាយខ័ណ្ឌរដ្ឋបាលព្រៃឈើ ខេត្តកំពត

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់របស់ក្រុមការងារ SAWAC ជាមួយលោក **ឱម ម៉ាកធារី** នាយខ័ណ្ឌរដ្ឋបាលព្រៃឈើខេត្តកំពត បានប្រព្រឹត្តិទៅនៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១០ វេលាម៉ោង០៩:០០នាទី ដល់ម៉ោង ១០:២០នាទីបានទទួលលទ្ធផល ដូចខាងក្រោម :

- សូមគាំទ្រគំរោងនេះ ដោយសារតម្រូវការថាមពលអគ្គិសនីសំរាប់ការអភិវឌ្ឍន៍ប្រទេសជាតិគឺមានសារៈសំខាន់ណាស់ ។ ទន្ទឹមនឹងនេះដែរយើងត្រូវសិក្សាផលប៉ះពាល់បរិស្ថានដោយសារគំរោងនេះគឺត្រូវរកឱ្យឃើញផលប៉ះពាល់អវិជ្ជមាន ដើម្បីដាក់ចេញនូវវិធានការទប់ស្កាត់ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានទាំងនោះ ។



Draft

- អនុសាសន៍របស់សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន គឺត្រូវសំអាតព្រៃឈើក្នុងអាង តែត្រូវធ្វើសារ ពើភ័ណ្ឌព្រៃឈើជាមុនសិន ដើម្បីធ្វើការដេញថ្លៃព្រៃឈើនេះ ។
- បច្ចុប្បន្ន ពុំទាន់មានការដេញថ្លៃព្រៃឈើនេះ ឡើយ គឺនៅរងចាំការធ្វើសារពើភ័ណ្ឌព្រៃឈើជាមុនសិន ។
- ការធ្វើសារពើភ័ណ្ឌនេះ គឺមានគណៈកម្មការថ្នាក់ជាតិមួយសំរាប់អនុវត្តន៍ការងារនេះ ។ ចំពោះខណ្ឌ័រដ្ឋបាលព្រៃឈើខេត្ត គ្រាន់តែជាសមាជិក នៃគណៈកម្មការនេះតែប៉ុណ្ណោះ ។
- សព្វថ្ងៃ ខណ្ឌ័រដ្ឋបាលព្រៃឈើ ខេត្តកំពត នៅរងចាំតែអនុវត្តន៍ការងារចុះបញ្ជីសារពើភ័ណ្ឌព្រៃឈើនេះតែប៉ុណ្ណោះ បើមានបញ្ជារពីគណៈកម្មការ ថាឱ្យធ្វើនោះ ។
- គួរមានការព្រួយបារម្ភផងដែរ ចំពោះការយឺតយ៉ាវការចុះបញ្ជីសារពើភ័ណ្ឌព្រៃឈើនេះ ព្រោះថាការងារត្រូវការរយៈពេលយូរ ហើយរដូវវស្សាកាន់តែជិតមកដល់ផងដែរ ។
- SAWAC គួរមានការស្នើសុំទៅក្រសួងបរិស្ថាន តាមបែបបទរដ្ឋបាល ឱ្យមន្ត្រីខណ្ឌ័រដ្ឋបាលព្រៃឈើ ខេត្តកំពត ធ្វើការរួមគ្នាក្នុងការសិក្សាស្រាវជ្រាវព្រៃឈើ ដែលត្រូវលិចដោយសារគំរោងនេះ ។ ព្រោះថា លទ្ធផលទទួលបានគឺដូចគ្នា ហើយលទ្ធផលនេះ គឺជាបរិមាណឈើដែលត្រូវសំអាតក្នុងអាង ហើយអាចយកវាទៅធ្វើការប្រកាសដេញថ្លៃតែ ម្តង ។

<u>**សំណូមពរ**</u> **:**

- សូមឱ្យការសិក្សាហេតុប៉ះពាល់បរិស្ថាននៅតំបន់គំរោង ធ្វើការអង្កេតឱ្យបានច្រើនលើហេតុប៉ះពាល់ធនធានបរិស្ថាន និង ប្រមូលព័តិមានឱ្យបានច្រើនដើម្បីរកវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមានសមស្រប និងមានប្រសិទ្ធិភាពខ្ពស់ ។
- ក្រុមហ៊ុនត្រូវមានមូលនិធិគ្រប់គ្រាន់សំរាប់ក្រុមការងាររដ្ឋបាលព្រៃឈើគ្រប់គ្រង ការពារ និងថែទាំធនធានធម្មជាតិនៅជុំវិញតំបន់គំរោង នេះ ។

### ៦.៣.៩ លទ្ធផល នៃការប្រជុំប្រឹក្សាយោបល់របស់ក្រុមការងារជាមួយនាយរងខ័ណ្ឌរដ្ឋបាលជលផល ខេត្តខេត្តកំពត

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ របស់ក្រុមការងារ SAWAC ជាមួយលោក **ថៃ សាម៉ន** នាយរងខ័ណ្ឌ រដ្ឋបាលជលផល ខេត្តកំពត បានប្រព្រឹត្តិទៅនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ វេលាម៉ោង ០២:០០ នាទី ដល់ម៉ោង ០៣:០០នាទី រសៀល បានទទួលលទ្ធផល ដូចខាងក្រោម :

- សូមគាំទ្រគំរោងនេះទាំងស្រុង ព្រោះថាថាមពលអគ្គិសនីជាតម្រូវការចាំបាច់ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ ។ តែយើង ត្រូវសិក្សាអង្កេត លើផលប៉ះពាល់ជីវចំរុះអវិជ្ជមាន ក្នុងតំបន់គំរោងនេះ ដើម្បីរកមធ្យោបាយកាត់បន្ថយ ។
- ក្រុមហ៊ុនត្រូវមានផែនការការពារ និងថែរក្សាធនធានធម្មជាតិ ដោយសហការជាមួយខណ្ឌ័រដ្ឋបាលជលផល ។ ក្នុងនោះត្រូវមានផែនការសកម្មភាពល្បាត និងសកម្មភាពថែរក្សាជីវៈចំរុះក្នុងអាង និងជុំវិញតំបន់គំរោង ។
- ក្នុងរយៈពេលសាងសង់ គុណភាពទឹកឈូ ថយចុះ ហើយឆ្នាំនេះ រីងរាក់ ទៀតផង ។
- តំបន់មាត់ពាម មានក្រពើ និងភេ ចំណែកឯនៅតាមព្រែកកំចាយ មានបង្កង ត្រីក្អែក/ត្រីខ្មៅ តានេល កាហែ ត្រីឆ្កង...... ។

Draft

- នៅផ្នែកខាងលើ មានអន្លង់ធំៗ សំបូរត្រីទៀតផង។
- ក្រោយពីសាងសង់ទំនប់វារីអគ្គិសនី ត្រីមួយចំនួន ពុំអាចចុះឡើងបានក្នុងរដូវបន្តពូជទេ។ គួរមានវិធានការប្រលែងពូជត្រីក្នុងអាង ដើម្បីកុំឱ្យត្រី និងបង្កង ទាំងនោះបាត់បង់ពូជ។

**សំណូមពរ :**

សូមឱ្យក្រុមការងារសហការជាមួយអ្នកនេសាទ ភូមិស្ពំប្រាំពីរ ភូមិបត់ក្បាលដំរី ភូមិមាត់ពាម ភូមិអណ្តូងជីម៉ុន ភូមិព្រៃត្នោត និងភូមិកំពង់គ្រែង ដើម្បីសិក្សាប្រភេទត្រី ចរាចរត្រី បរិមាណផលនេសាទ ក្នុង និងផ្នែកខាងក្រោមតំបន់គំរោងនេះ ។

### ៦.៣.១០ លទ្ធផលនៃការប្រជុំប្រឹក្សាយោបល់របស់ក្រុមការងារជាមួយប្រធានឧទ្យានជាតិព្រះមុនីវង្ស បូកគោ

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់របស់ក្រុមការងារ SAWAC ជាមួយលោក **យ៉ង ភិរម្យ** ប្រធានឧទ្យានជាតិព្រះមុនីវង្ស បូកគោ បានប្រព្រឹត្តិទៅនៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១០ វេលាម៉ោង០២:០០នាទី ដល់ម៉ោង ០៣:០០នាទីរសៀល បានទទួល លទ្ធផល ដូចខាងក្រោម :

- គំរោងវារីអគ្គិសនីស្ទើរតែទាំងស្រុងស្ថិតក្នុងឧទ្យានជាតិព្រះមុនីវង្សបូកគោនេះ ដូចនេះក្រុមហ៊ុនត្រូវតែមានការសហការល្អ ជាមួយឧទ្យានុរក្ស ក្នុងការការពារ និងអភិរក្សធនធានធម្មជាតិជុំវិញ និងក្នុងតំបន់គំរោងនេះ។
- បច្ចុប្បន្ន ពុំទាន់មានការដេញថ្លៃព្រៃឈើនេះ ឡើយ គឺនៅរងចាំការធ្វើសារពើភ័ណ្ឌព្រៃឈើជាមុនសិន។
- សព្វថ្ងៃយើងមានគណៈកម្មការវាយតំលៃព្រៃឈើរួចហើយ ដូចនេះការធ្វើសារពើភ័ណ្ឌព្រៃឈើនេះ យើងចាំតែអនុវត្តន៏ប៉ុណ្ណោះបើមានថវិកា និងបញ្ជាពីគណៈកម្មការខាងលើ ពីព្រោះការងារនេះ គឺមានតែរដ្ឋបាលព្រៃឈើ និងឧទ្យានជាតិបូកគោប៉ុណ្ណោះ ដែលត្រូវអនុវត្តន៏។
- ចំពោះបញ្ហាគណនេយ្យបូនសូមក្រុមការងារ SAWAC ទំនាក់ទំនងទៅលោក ទិន ពន្លក ព្រោះគាត់ទទួលបន្ទុកលើការងារនេះ។
- ចំពោះសត្វព្រៃក្នុងតំបន់ឧទ្យានជាតិនេះ គេឃើញមានសត្វខ្ចីងកើនឡើង ខ្លាមានបីក្បាលដែលតែងប្រទះឃើញដើរក្បែរតំបន់គំរោងផងដែរ។ អ្នកនេសាទតែងចាប់បានសត្វកន្ធាយ កណ្តើក ហើយមានព័តិមានថាមានសត្វក្រពើទៀតផង។

**សំណូមពរ :**

សូមឱ្យក្រុមការងារ ទទួលយកមន្ត្រីឧទ្យានម្នាក់នាំផ្លូវ និងផ្តល់ព័តិមានជូន ដើម្បីធ្វើការប្រុងប្រយ័ត្នក្នុងការងារសិក្សានេះ។

Draft

### ៦.៣.១១ លទ្ធផលនៃការប្រជុំប្រឹក្សាយោបល់ខាងក្រុមការងារជាមួយប្រធាននាយកទទួលបន្ទុកកិច្ចការពាណិជ្ជកម្ម និងគ្រប់គ្រងកុងត្រា របស់ក្រុមហ៊ុន

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់របស់ក្រុមការងារ SAWAC ជាមួយលោក **Xi Peng** នាយកទទួលបន្ទុកកិច្ចការពាណិជ្ជកម្ម និងគ្រប់គ្រងកុងត្រារបស់ក្រុមហ៊ុន **Sinohydro** បានប្រព្រឹត្តិទៅនៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១០ វេលាម៉ោង ០២:០០ នាទី ដល់ម៉ោង ០៣:០០នាទី រសៀល បានទទួលលទ្ធផល ដូចខាងក្រោម :

- ក្រុមហ៊ុននឹងផ្តល់ឯកសារពាក់ព័ន្ធជូន ដល់ក្រុមការងារ SAWAC បើសិនត្រូវការ ។
- ចំពោះ ការប៉ះពាល់ដីប្រើប្រាស់ ក្រុមហ៊ុន រួមជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងគណៈកម្មការខេត្ត បាន ដោះស្រាយសំណង ជូនប្រជាពលរដ្ឋរួចរាល់ហើយ ។
- ក្រុមហ៊ុននឹងសហការជាមួយក្រុមការងារ SAWAC គ្រប់ពេលវេលា ។

<u>សំណូមពរ :</u>

- សូមឱ្យក្រុមការងារ SAWAC ថតរូប ដើម្បីធ្វើស្លាកសំគាល់ដោយក្រុមហ៊ុន **Sinohydro** សំរាប់ងាយស្រួលក្នុងការចេញ-ចូល ក្នុងតំបន់គំរោង ។

### ៦.៣.១២ លទ្ធផលនៃការប្រជុំប្រឹក្សាយោបល់ខាងក្រុមការងារជាមួយឃុំម៉ាក់ប្រាង

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ របស់ក្រុមការងារ SAWAC ជាមួយលោក **សេង សាយ** មេឃុំម៉ាក់ប្រាង ស្រុកទឹកឈូ ខេត្តកំពត បានប្រព្រឹត្តិទៅនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០ វេលាម៉ោង ០៨:៣០០ នាទី ដល់ម៉ោង ០៩:៣០នាទី ព្រឹក បានទទួលលទ្ធផល ដូចខាងក្រោម :

- សូមគាំទ្រគំរោងនេះទាំងស្រុង ព្រោះថា ប្រជាពលរដ្ឋក្នុងឃុំត្រូវការភ្លើងអគ្គិសនីប្រើប្រាស់ ដែលមានតំលៃថោក ។
- ក្រុមហ៊ុនត្រូវមានផែនការការពារ និងថែរក្សាធនធានធម្មជាតិ នៅជុំវិញតំបន់គំរោង ដើម្បីផលប្រយោជន៍របស់ប្រជាពលរដ្ឋផង និងធ្វើឱ្យមានលំនឹង នៃរបបទឹកភ្លៀង នៅតំបន់គំរោងផង ។
- ក្រុមហ៊ុនត្រូវពិនិត្យមើលការជំរាបទឹក និងការហូរច្រោះតាមជ្រលងភ្នំ ហើយមានវិធានការសាង់សង់ជំរាលបេតុងនៅតាមច្រលងនោះ ជៀសវាងការបាក់ភ្នំបង្កគ្រោះមហន្តរាយដល់ប្រជាពលរដ្ឋ ដែលរស់នៅផ្នែកខាងក្រោមតំបន់គំរោង ។ ក្រុមហ៊ុន ត្រូវកាយថ្មបាំងមុខទឹក ដែលហូរចុះមកកន្លែងកំសាន្តទឹកឈូ ។
- ក្រុមហ៊ុនគួរសង់ទំនប់ទប់ទឹកប្រៃ នៅផ្នែកខាងក្រោមស្ថានីយបូមទឹកចាស់របស់ខេត្តកំពត ដើម្បីរក្សាពូជត្រីទឹកសាបមួយចំនួន និងធ្វើឱ្យការផ្គត់ផ្គង់ទឹកសាប ក្នុងការដាំដំណាំហូបផ្លែ របស់ប្រជាពលរដ្ឋមួយចំនួន ផង ។
- ការប៉ះពាល់ប្រព័ន្ធខ្សែចំលង ក្នុងឃុំ មានតែភូមិមាត់ពាម ប៉ុណ្ណោះ ។

<u>សំណូមពរ :</u>

- សូមឱ្យក្រុមហ៊ុនធ្វើការស្រោចទឹកតាមផ្លូវដីកថ្ម ទៅកាន់តំបន់គំរោងឱ្យបានជាប្រចាំ និងសូមឱ្យជួសជុលផ្លូវដីកថ្មនេះឱ្យមាន លក្ខណៈស្មើល្អ អាចប្រើប្រាស់បានយូរអង្វែង ។
- សូមឱ្យមានសំណងសមស្រប ជូនប្រជាពលរដ្ឋលើការប៉ះពាល់ប្រព័ន្ធខ្សែចំលងនេះ ។

### ៦.៣.១៣ លទ្ធផល នៃការប្រជុំប្រឹក្សាយោបល់របស់ក្រុមការងារជាមួយឃុំកំពង់ត្រែង

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ របស់ក្រុមការងារ SAWAC ជាមួយលោក **មិត ណាង** មេឃុំកំពង់ត្រែង ស្រុកទឹកឈូ ខេត្តកំពត បានប្រព្រឹត្តិទៅនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១០ វេលាម៉ោង ០៨:៣០០ នាទី ដល់ម៉ោង ០៩:៣០នាទី ព្រឹក បានទទួលលទ្ធផល ដូចខាងក្រោម :

- សូមគាំទ្រគំរោងនេះ១០០% ព្រោះថា ថាមពលអគ្គិសនី ជាតំរូវចាំបាច់សំរាប់ការអភិវឌ្ឍន៍ភូមិ-ឃុំ និងប្រទេសជាតិទាំងមូល ។
- ការប៉ះពាល់ប្រព័ន្ធខ្សែចំលង ក្នុងឃុំ មានភូមិអណ្តូងជីម៉ឺន ភូមិបាក់ប្រាង និងកំពង់ក្រុង ។
- ពេលសាងសង់ប្រព័ន្ធខ្សែចំលង គួរធ្វើនៅរដូវប្រាំង កុំឱ្យខូចខាចដំណាំស្រូវ របស់ប្រជាពលរដ្ឋ ។
- ក្រុមហ៊ុនគួរធ្វើការស្រោចទឹកតាមផ្លូវដឹកថ្មទៅកាន់តំបន់គំរោងឱ្យបាន១ដង ទៅ២ដង ក្នុង១ថ្ងៃ ព្រោះនៅរដូវប្រាំងខាងមុខនេះ ស្ថានភាពផ្លូវហុយសំណើមណាស់ នឹងធ្វើឱ្យប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ យ៉ាងខ្លាំង ។
- នៅជុំវិញតំបន់គំរោងវារីអគ្គិសនីកំចាយនេះ ក្រុមហ៊ុនត្រូវដាំដើមឈើជុំវិញតំបន់គំរោង ដើម្បីរក្សាលំនឹងបរិស្ថាន និងរបបទឹកភ្លៀងឱ្យបានទៀងទាត់ ។

__សំណូមពរ__ :

- សូមឱ្យក្រុមហ៊ុនដោះស្រាយសំណងឱ្យបានសមស្របជូនប្រជាពលរដ្ឋ ដែលត្រូវប៉ះពាល់ដី និងដំណាំ ដោយសារការសាងសង់ បង្គោលភ្លើង និងការវាយខ្សែបណ្តាញខ្សែតង់ស្យុងខ្ពស់ នេះ ។
- សូមឱ្យក្រុមហ៊ុនសាងសង់ប្រព័ន្ធខ្សែបណ្តាញអគ្គិសនីត្រូវតាមស្តង់ដាបច្ចេកទេស ហើយទាញខ្សែចំលងអគ្គិសនីឱ្យបានតឹង ព្រោះប្រជាពលរដ្ឋខ្លាចរងក់ ។
- សូមឱ្យក្រុមហ៊ុនសរសេរស្លាកសញ្ញាសំគាល់គ្រោះថ្នាក់ ជាប់ទៅនឹងបង្គោលភ្លើង ហើយត្រូវមានប្រព័ន្ធផ្តាច់ចរន្តភ្លើង នៅពេលមានហេតុការណ៍ ទុស្សេ ឬដាច់ខ្សែភ្លើងម្តងៗ ។
- ចំពោះការប៉ះពាល់កន្លែងកំសាន្តទឹកឈូ សូមឱ្យក្រុមហ៊ុនកាយថ្មបាំងមុខទឹក ដែលហូរចុះមកកន្លែងកំសាន្តទឹកឈូ ដើម្បីឱ្យទឹកហូរបានខ្លាំង សំរាប់ឱ្យភ្ញៀវទេសចរអាចមកហែលទឹកកំសាន្តបាន ។ ជាងនេះទៅទៀត សូមកុំឱ្យក្រុមហ៊ុន បិទទឹកធ្វើឱ្យដាច់ទឹកនៅកន្លែងកំសាន្តទឹកឈូនេះឱ្យសោះ ព្រោះប៉ះពាល់ដល់ជីវភាពប្រជាពលរដ្ឋ ដែលពឹងផ្អែកទាំងស្រុងលើមុខរបរ ទេសចរណ៍នេះ ។
- សូមឱ្យក្រុមហ៊ុនជួសជុលផ្លូវដឹកថ្ម ទៅកាន់តំបន់គំរោង ឱ្យមានលក្ខណៈស្មើល្អឡើងវិញ នៅពេលបញ្ចប់ការងារដឹកថ្មនេះ និងដាក់លូ នៅចំណុចអូរអន្លង់ក្រញូង នៅភូមិអណ្តូងជីម៉ឺន ដើម្បីបញ្ចៀសទឹកជំនន់ ។

### ៦.៣.១៤ លទ្ធផល នៃការប្រជុំប្រឹក្សាយោបល់របស់ក្រុមការងារជាមួយឃុំព្រៃឃ្មុំ

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ របស់ក្រុមការងារ SAWAC ជាមួយលោក **ពុយ យ៉ា** ជំទប់ទី១ ឃុំព្រៃឃ្មុំ ស្រុកទឹកឈូ ខេត្តកំពត បានប្រព្រឹត្តិទៅនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ វេលាម៉ោង ០៨:៣០ នាទី ដល់ម៉ោង ០៩:៣០នាទី ព្រឹក បាន ទទួលលទ្ធផល ដូចខាងក្រោម :

- សូមគាំទ្រគំរោងនេះ១០០% ព្រោះថា ប្រជាពលរដ្ឋចង់បានភ្លើងអគ្គិសនីប្រើប្រាស់ និងតំលៃថោក ។

- ការប៉ះពាល់ប្រព័ន្ធខ្សែចំលង ក្នុងឃុំ មានតែភូមិ ព្រៃឃ្មុំ មួយប៉ុណ្ណោះ ។
- ពេលសាងសង់ប្រព័ន្ធខ្សែចំលង គួរធ្វើនៅរដូវប្រាំង កុំឱ្យខូចខាតដំណាំស្រូវ របស់ប្រជាពលរដ្ឋ ។

**<u>សំណូមពរ :</u>**

- សូមឱ្យក្រុមហ៊ុនសាងសង់ប្រព័ន្ធខ្សែបណ្តាញអគ្គិសនីត្រូវតាមស្តង់ដាបច្ចេកទេសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។
- ក្រុមហ៊ុនត្រូវផ្សព្វផ្សាយអំពីសុវត្ថិភាពនៃប្រព័ន្ធខ្សែចំលងនេះ និងមានប្រព័ន្ធការពារដោយស្វ័យប្រវត្តិ ជៀសវាងមានគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋ ។
- សូមឱ្យក្រុមហ៊ុនដោះស្រាយសំណងសមស្រប ជូនប្រជាពលរដ្ឋ ចំពោះការប៉ះពាល់ដីស្រែ ឬដីភូមិ និងដំណាំរបស់ពួកគាត់ ដោយសារការសាងសង់បង្គោលភ្លើង និងខ្សែចំលងតង់ស្យុងខ្ពស់ របស់ក្រុមហ៊ុន។

### ៦.៣.១៥ លទ្ធផល នៃការប្រជុំប្រឹក្សាយោបល់ជាមួយក្រុមការងារជាមួយឃុំព្រៃថ្នង តំពង់ត្រែង

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ របស់ក្រុមការងារ SAWAC ជាមួយលោក **ពង់ សាន់** មេឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត បានប្រព្រឹត្តិទៅនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១០ វេលាម៉ោង ០៩:៣០ នាទី ដល់ម៉ោង ១០:៣០នាទី ព្រឹក បានទទួល លទ្ធផល ដូចខាងក្រោម :

- សូមគាំទ្រគំរោងនេះ១០០% ព្រោះថា ប្រជាពលរដ្ឋចង់បានភ្លើងអគ្គិសនីប្រើប្រាស់ និងតំលៃថោក ។
- កន្លែងយកថ្មនៅភ្នំដុមមាន់ព្រៃ និងភ្នំដុមជ្រឹង ស្ថិតនៅភូមិ ទ្វារថ្មី ធ្វើឱ្យមានការប៉ះពាល់ដល់ការរស់នៅ របស់ប្រជាពលរដ្ឋធ្ងន់ធ្ងរដែរ តែការប៉ះពាល់នេះត្រូវបានដោះស្រាយដោយគណៈកម្មការរបស់ខេត្ត រួចហើយ ដូចជា ការជំលៀសប្រជាពលរដ្ឋ ឱ្យរស់នៅឆ្ងាយជាងព្រំប្រទល់នៃការដ្ឋានបំផ្ទុះ ១០០ម៉ែត្រ ដោយក្រុមហ៊ុនជួលដី ប្រជាពលរដ្ឋ ក្នុងឯកត្តា ១ហិកតា ៥០០០ ដុល្លារ ក្នុងរយៈពេល ៣ឆ្នាំ ។ ក្នុងកិច្ចសន្យា កំណត់ថា អ្នកដែលរស់នៅឆ្ងាយជាង ១០០ ម៉ែត្រ ពី ព្រំប្រទល់ការដ្ឋានយកថ្ម មិនត្រូវបានជួលដីនោះទេ តែបើមានថ្មខ្ទាតប៉ះពាល់ផ្ទះ ក្រុមហ៊ុននឹងចេញសងថ្លៃការខូចខាតនេះ ។ ចំពោះអ្នករស់នៅក្នុងរង្វង់១០០ ម៉ែត្រ ពីព្រំប្រទល់នៃការដ្ឋានយកថ្ម នោះក្រុមហ៊ុនត្រូវជួលដីតាមតំលៃឯកត្តាខាងលើ តែមិនមានសំណងអ្វីឡើយ បើមានការខូចខាតផ្ទះសម្បែង ឬអ្វីមួយ។ អ្នកដែលត្រូវបានក្រុមហ៊ុនជួល ដីមានចំនួន ១៥គ្រួសារ ។
- មានពាក្យបណ្តឹងម្តងដែរ នៅពេលមានដុំថ្មប៉ះពាល់ផ្ទះសម្បែងរបស់ប្រជាពលរដ្ឋ ពេលនោះក្រុមហ៊ុនបានដោះស្រាយសំណងរួចហើយ តែមានប្រជាពលរដ្ឋមួយចំនួនថា ពុំបានទទួលសំណងនោះទេ ហើយខ្លះថាសំណងនេះមានការយឺតយ៉ាវបំផុត។ ការដោះស្រាយនេះ មេឃុំមិនបានចូលរួមទេ គឺចិនសហការតែជាមួយជាមួយប្រធានភូមិប៉ុណ្ណោះ ។
- ចំពោះបញ្ហាផ្លូវ ក្រុមហ៊ុនគេទិញពីប្រជាពលរដ្ឋដាច់តែម្តង ក្រោយចប់អាណត្តិយកថ្មនេះ ក្រុមហ៊ុននឹងប្រគល់ផ្លូវនេះជូនទៅឱ្យអាជ្ញាធរដែនដីគ្រប់គ្រងបន្ត ។
- ក្រុមហ៊ុនមានវិធានការស្រោចទឹកតាមផ្លូវដឹកថ្មដែរ តែការអនុវត្តបានតិចតួចប៉ុណ្ណោះ ។

**សំណូមពរ :**

- ក្រោយពេលបញ្ចប់ការងារដីកថ្ម សូមឱ្យក្រុមហ៊ុនជួសជុលផ្លូវដីកថ្ម នេះឡើងវិញ ដើម្បីទុកឱ្យប្រជាពលរដ្ឋងាយស្រួលក្នុងការធ្វើដំណើរ និងដឹកជញ្ជូនផលិតផលកសិកម្ម ។
- សូមឱ្យក្រុមហ៊ុន ឬអាជ្ញាធរអគ្គិសនីកម្ពុជា តបណ្តាញអគ្គិសនី ឱ្យប្រជាពលរដ្ឋរស់ក្នុងឃុំព្រៃថ្នង មានអគ្គិសនីប្រើប្រាស់ និង តំលៃថោក ។

**៦.៣.១៦ លទ្ធផល នៃការប្រជុំប្រឹក្សាយោបល់របស់ក្រុមការងារជាមួយប្រធានមណ្ឌលសុខភាពកំពង់ត្រែង**

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ របស់ក្រុមការងារ SAWAC ជាមួយលោក **ចាន់ សារី** ប្រធានមណ្ឌលសុខភាពកំពង់ត្រែង ឃុំកំពង់ត្រែង បានប្រព្រឹត្តិទៅនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១០ វេលាម៉ោង ០៨:៣០ នាទី ដល់ម៉ោង ០៩:៣០នាទី ព្រឹក បានទទួលលទ្ធផល ដូចខាងក្រោម :

- សូមគាំទ្រគំរោងនេះ១០០% ព្រោះថា ប្រជាពលរដ្ឋចង់បានភ្លើងអគ្គិសនីប្រើប្រាស់ និងតំលៃថោក ។
- បុគ្គលិកពេទ្យ មាន៥នាក់ និងបុគ្គលិកបណ្តែត ០១នាក់ ។ មណ្ឌលសុខភាព នេះមាន៦បន្ទប់ ។
- អ្នកជំងឺមធ្យម ៥០០នាក់ ក្នុង ១ខែ ។ ប្រភេទជំងឺ មានច្រើន គឺផ្តាសាយ និងរាគ ។
- បច្ចុប្បន្នជំងឺរាគ ឃើញមានអត្រាខ្ពស់ជាង មុនពេលសាងសង់ទំនប់វារីអគ្គិសនីកំចាយ នេះ ។ ចំពោះជំងឺសើរស្បែក ឃើញមានកើត ច្រើនទៅលើប្រជាពលរដ្ឋ ដែលមានលំនៅដ្ឋានក្នុងតំបន់ទឹកឈូ ។

**សំណូមពរ :**

សូមឱ្យក្រុមហ៊ុនសាងសង់អាងចំរោះទឹកកខ្វក់ មុនទំលាក់មកផ្នែកខាងក្រោម ជៀសវាងប៉ះពាល់សុខភាពប្រជាពលរដ្ឋ និងភ្ញៀវ ទេសចរ ។

**៦.៣.១៧ លទ្ធផលនៃការប្រជុំប្រឹក្សាយោបល់របស់ក្រុមការងារជាមួយប្រធានមន្ទីរទេសចរណ៍ ខេត្តកំពត**

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ របស់ក្រុមការងារ SAWAC ជាមួយលោក **សយ ស៊ីណុល** ប្រធានមន្ទីរទេសចរណ៍ ខេត្តកំពត បានប្រព្រឹត្តិទៅនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ វេលាម៉ោង ០២:៣០ នាទី ដល់ម៉ោង ០៣:៣០នាទី ល្ងាចបាន ទទួលលទ្ធផល ដូចខាងក្រោម :

- សូមគាំទ្រគំរោងនេះ ១០០% ព្រោះថា តម្រូវការថាមពលអគ្គិសនីសំរាប់ការអភិវឌ្ឍន៍ប្រទេសជាតិ និងការប្រើប្រាស់របស់ប្រជាពលរដ្ឋ គឺជាការចាំបាច់ណាស់ ។
- ការថយចុះចំនួនទេសចរណ៍អាចបណ្តាលមកពីស្ពានយោងដាច់ មិនអាចឆ្លងបាន ។

**សំណូមពរ :**

សូមឱ្យក្រុមការងារ សិក្សាបន្ថែមទៀត ដើម្បីឱ្យដឹងថា មានផលប៉ះពាល់អ្វីខ្លះ ។

**៦.៣.១៨ លទ្ធផលនៃការប្រជុំប្រឹក្សាយោបល់របស់ក្រុមការងារជាមួយចៅសង្កាត់អណ្តូងខ្មែរ**

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ របស់ក្រុមការងារ SAWAC ជាមួយលោក **យ៉យ ស៊ីថន** ចៅសង្កាត់អណ្តូងខ្មែរ បានប្រព្រឹត្តិទៅនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១០ វេលាម៉ោង ០៨:៣០ នាទី ដល់ម៉ោង ៩:៣០នាទី ព្រឹក បានទទួលលទ្ធផល ដូចខាងក្រោម :



Draft

- សូមគាំទ្រគំរោងនេះ ១០០% ព្រោះថាការផ្គត់ផ្គង់ថាមពលអគ្គិសនីរបស់រដ្ឋសំរាប់ប្រជាពលរដ្ឋ នៅមានការខ្វះខាតច្រើន ។
- ប្រជាពលរដ្ឋ ដែលប្រកបមុខរបរអនុផលព្រៃឈើ ភាគច្រើនរស់នៅភូមិអូរតូច ដូចនេះ ប្រជាពលរដ្ឋទាំងនោះ គួរចូលរួមជាមួយសហគមន៍រក្សាព្រៃឈើ ដាំផ្តៅ និងឫស្សី នៅភូមិអូរតូច ព្រោះថា ផ្ទៃដីព្រៃរបស់សហគមន៍នេះ មានចំនួនច្រើនដែរ គឺរហូត ដល់ទៅ ៤៣៥ហិកតា ឯណោះ ។

**សំណូមពរ :**

សូមឱ្យក្រុមហ៊ុន ជួយថែរក្សាព្រៃឈើជុំវិញតំបន់គំរោងឱ្យបានគង់វង្ស ជៀសវាងការហូរច្រោះ និងផលប៉ះពាល់បរិស្ថានផ្សេងទៀត ។

### ៦.៤ លទ្ធផលនៃការប្រជុំប្រឹក្សាយោបល់ជាសាធារណៈ អាជ្ញាធរដែនដី ជាមួយអង្គភាព និងប្រជាពលរដ្ឋពាក់ព័ន្ធ

លទ្ធផលនៃការប្រជុំប្រឹក្សាយោបល់ជាសាធារណៈជាមួយ អាជ្ញាធរដែនដី អង្គភាព និងប្រជាពលរដ្ឋពាក់ព័ន្ធ នេះ បានធ្វើឡើងតាម រយៈការប្រជុំ និងសំភាសន៍ ដែលមានអ្នកចូលរួមចំនួន ២៣៣ នាក់ ក្នុងនោះ អាជ្ញាធរ និងអង្គភាពពាក់ព័ន្ធចំនួន ១៨នាក់ ហើយនឹងប្រជាពលរដ្ឋ ចំនួន ២១៥ នាក់ លទ្ធផលដូចមានក្នុងតារាង៦៥ខាងក្រោម:

**តារាងលេខ៦៥ : លទ្ធផល នៃការប្រឹក្សាពិគ្រោះយោបល់ និងសំភាសន៍**

| មតិ និង អនុសាសន៍ | មតិចូលរួម | វិធានការកាត់បន្ថយ |
|---|---|---|
| អាជ្ញាធរខេត្ត ស្រុក ឃុំ និងភូមិ ព្រមទាំងមន្ទីរពាក់ព័ន្ធមួយចំនួនរបស់ខេត្តកំពតចង់បានកិច្ចសហប្រតិបត្តិការល្អពីក្រុមហ៊ុនវិនិយោគ គំរោងវារីអគ្គិសនីកំចាយនេះ ដើម្បីទទួលបាននូវព័ត៌មានរបស់គំរោង ហើយរួមគ្នាដោះស្រាយបញ្ហានានា ដែលក្រុមហ៊ុនជួបប្រទះ ។ | ១៤ | ក្រុមហ៊ុនត្រូវបង្កើនការសហការ និងទំនាក់ទំនងការងារយ៉ាងសកម្មជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ទីរពាក់ព័ន្ធមួយ ចំនួនដើម្បីផ្តល់ព័ត៌មានទៅវិញទៅមក ដើម្បីរួមគ្នាដោះស្រាយបញ្ហា នានាដែលក្រុមហ៊ុនជួបប្រទះ ។ |
| ក្រុមហ៊ុនត្រូវសំអាតទឹកកខ្វក់ចេញពីបង្គន់ បន្ទប់ទឹក ផ្ទះបាយ មុនបង្ហូរទឹកកខ្វក់នេះមកផ្នែកខាងក្រោមតំបន់គំរោង។ | ៣ | ក្រុមហ៊ុនត្រូវធ្វើអាងសំអាតទឹកកខ្វក់ចេញពីបង្គន់ បន្ទប់ទឹក ផ្ទះបាយ និងបន្តធ្វើបន្ថែមទៀត សំរាប់កន្លែងស្នាក់នៅ ដែលសង់ថ្មីៗ ដើម្បីកាត់បន្ថយការបំពុលបរិស្ថាន ផ្នែកខាងក្រោមតំបន់គំរោងនេះ ។ |
| ក្រុមហ៊ុនគួរសហការជាមួយក្រុមហ៊ុនដឹកសំរាមរបស់ ខេត្ត ក្នុងការចោលសំរាម ។ | ២ | ក្រុមហ៊ុនត្រូវធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុនដឹកសំរាមរបស់ខេត្តកំពត ដោយមានការដឹងឮពីអាជ្ញាធរមូលដ្ឋានផងដែរ ដើម្បីធានាឱ្យការដឹកសំរាមនេះ មានដំណើរការល្អប្រសើរ ។ |
| ក្រុមហ៊ុនគួរស្រោចទឹកជាប្រចាំតាមផ្លូវដែលក្រុមហ៊ុនបានដឹកថ្មរាល់ថ្ងៃ ជាពិសេស នៅចំណុចទីប្រជុំជន ដើម្បីការពារសុខភាពប្រជាពលរដ្ឋ ។ | ៥០ | ក្រុមហ៊ុនត្រូវរៀបចំកំលាំងប្រជាពលរដ្ឋបន្ថែមទៀតសំរាប់ធ្វើការស្រោចទឹកតាមផ្លូវ ដែលក្រុមហ៊ុនបានដឹកថ្មរាល់ថ្ងៃ ជាពិសេស នៅចំណុចទីប្រជុំជន ឱ្យបានជាប្រចាំ ។ |
| ក្រុមហ៊ុនបានធ្វើផ្លូវសំរាប់ដឹកថ្ម ទៅតំបន់គំរោង តែនៅកន្លែងផ្លូវទឹកឬអូរមិនបានដាក់លូរ ឬសង់ស្ពាននោះទេ ជាហេតុធ្វើឱ្យមានការលិចលង់ក្នុងរយៈពេលយូរសំរាប់ភូមិ នៅប៉ែកខាងលើ | ៣ | ក្រុមហ៊ុនត្រូវមានផែនការដាក់លូរ ឬធ្វើស្ពាន គ្រង់ចំណុចផ្លូវទឹក ឬអូរ តាមផ្លូវដឹកថ្ម ពីផ្លូវជាតិលេខ៣ មកតំបន់គំរោងឱ្យបានសមស្របតាម លក្ខណៈបច្ចេកទេស ។ |

Draft

| | | |
|---|---|---|
| និងធ្វើឱ្យខូចខាតផ្ទះសម្បែង និងផលដំណាំ ឬជីវិតមនុស្ស-សត្វ នៅពេលមានទឹកជំនន់ ។ | | |
| ចំនួនទេសចរមកលេងតំបន់រមណីយដ្ឋានទឹកឈូមានការថយចុះពី៥០-៨០ភាគរយ ដោយសារគុណភាពទឹកស្ទឹងទឹកឈូ មានភាពកខ្វក់ ។ | ៣២ | ក្រុមហ៊ុន ត្រូវគ្រប់គ្រងការបញ្ចេញកាកសំណល់គ្រប់ប្រភេទ ដើម្បីកុំឱ្យផ្នែកខាងក្រោមទំនប់ទី២នេះ ឈានដល់ការបំពុលទឹក ។ |
| សព្វថ្ងៃមានការសំអាតព្រៃ ក្នុងអាងវារីអគ្គិសនីក្នុងតំលៃ ២០០ ដុល្លារ/ហិកតា តែមិនដឹងថាមានបង្កើតគណៈកម្មការរបស់រដ្ឋាភិបាលត្រួតពិនិត្យការសំអាតឈើនេះ ដែរឬទេ? | ៣ | ក្រុមហ៊ុនត្រូវសហការជាមួយក្រុមការងារ SAWAC សិក្សាបរិមាណឈើដែលត្រូវសំអាតក្នុងអាងនេះ ហើយលទ្ធផលក្រុមការងារ SAWAC នឹងធ្វើរបាយការណ៍ជូនរដ្ឋាភិបាល ។ |
| ការសាងសង់នេះហាក់ដូចពុំមានទំនប់បំរុងសំរាប់ការពារបរិមាណទឹកក្នុងករណីបាក់ទំនប់ទី១ នៅពេលមានទឹកជំនន់ធំៗ កើតឡើងនៅរដូវវស្សា ។ | ២ | ក្រុមហ៊ុនត្រូវមានទំនប់បំរុង សំរាប់ការពារបរិមាណទឹក ក្នុងករណីបាក់ទំនប់ទី១ នៅពេលមានទឹកជំនន់ធំៗ កើតឡើង នៅរដូវវស្សា ។ |
| ក្រោយពីសាងសង់ទំនប់វារីអគ្គិសនី ត្រីមួយចំនួន ពុំអាចចុះឡើងបានក្នុងរដូវបន្តពូជទេ។ គួរមានវិធានការប្រលែងពូជត្រី ក្នុងអាង ដើម្បីកុំឱ្យត្រីទាំងនោះ បាត់បង់ពូជ ។ | ៦១ | ក្រុមហ៊ុនត្រូវមានផែនការទំនប់ទប់ទឹកប្រៃ ដើម្បីជួយថែរក្សាប្រភេទត្រីដែលចុះពីតំបន់គំរោង ហើយឡើងវិញមិនរួច បានរស់នៅផ្នែកខាងក្រោមទំនប់ទី២ ឬ សាងសង់ស្ថានីយ៍ភ្ញាស់កូនត្រីពូជ ដែលត្រូវបាត់បង់ ដោយសារ ការសាងសង់ទំនប់វារីអគ្គិសនី នេះ ។ |
| គួរធ្វើជើងទេរជាថ្នាក់ៗដើម្បីការពារការហូរច្រោះដី និងបាក់ថ្មជៀសវាងបង្កគ្រោះថ្នាក់ច្រើនយ៉ាង ក្នុងតំបន់គំរោង និងផ្នែកខាងក្រោមតំបន់គំរោង ។ | ១៥ | ក្រុមហ៊ុនត្រូវរៀបធ្វើជើងទេរនៅទីតាំងមួយចំនួន ដែលពិនិត្យឃើញថា ទីតាំងនោះ អាចនឹងមានការហូរច្រោះ ធ្វើបាក់ថ្ម ឬដីបង្កគ្រោះថ្នាក់ ឬ ខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធគំរោង ។ |
| ក្រុមហ៊ុនត្រូវកាយថ្មបាំងមុខទឹក ដែលហូរចុះមកកន្លែង កំសាន្តទឹកឈូ ដើម្បីកុំឱ្យដាច់ទឹក និងមានចរន្តទឹកហូរ សំរាប់ភ្ញៀវទេសចរកំសាន្ត ។ | ៣២ | ក្រុមហ៊ុនត្រូវជួលកំលាំងពលកម្មប្រជាពលរដ្ឋ ឬប្រើគ្រឿងចក្រកាយថ្មបាំងមុខទឹកនេះចេញ ដើម្បីធ្វើឱ្យមានចរន្តទឹកហូរ អាចឱ្យភ្ញៀវទេសចរកំសាន្តបាន ។ |
| ក្រុមហ៊ុនគួរសង់ទំនប់ទប់ទឹកប្រៃ នៅផ្នែកខាងក្រោមស្ថានីយ៍បូមទឹកចាស់របស់ខេត្តកំពត ដើម្បីរក្សាពូជត្រីទឹកសាប មួយចំនួន និងផ្គត់ផ្គង់ទឹកសាប ក្នុងការដាំដំណាំហូបផ្លែ របស់ប្រជាពលរដ្ឋ មួយចំនួន ផង ។ | ៦៥ | ក្រុមហ៊ុនត្រូវមានផែនការសាងសង់ទំនប់នេះ ។ |
| ការសាងសង់ប្រព័ន្ធខ្សែចំលង គួរធ្វើនៅរដូវប្រាំងកុំឱ្យខូចខាតដំណាំស្រូវ របស់ប្រជាពល់រដ្ឋ ។ | ១០ | ក្រុមហ៊ុនត្រូវសាងសង់ប្រព័ន្ធខ្សែចំលង នៅរដូវប្រាំង មិនឱ្យប៉ះពាល់ដំណាំស្រូវវស្សា របស់ប្រជាពលរដ្ឋ ។ |
| ក្រុមហ៊ុនគួរធ្វើការស្រោចទឹកតាមផ្លូវដឹកថ្មទៅកាន់តំបន់គំរោងឱ្យបាន១ដង ទៅ២ដង ក្នុង១ថ្ងៃ ព្រោះនៅរដូវប្រាំង ស្ថានភាពផ្លូវហុយខ្លាំង នឹងធ្វើឱ្យប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ ។ | ៤១ | ក្រុមហ៊ុនត្រូវប្រើរថយន្តដឹកទឹក និងកន្លែងខ្លះជួលប្រជាពលរដ្ឋឱ្យស្រោចទឹក លើផ្លូវដឹកថ្មនេះ មិនឱ្យហុយដីប៉ះពាល់សុខភាពប្រជាពលរដ្ឋ ។ |
| សំណូមពរ | មតិចូលរួម | ដំណោះស្រាយ |

Draft

| | | |
|---|---|---|
| សូមឱ្យក្រុមការងារសិក្សាផលប៉ះពាល់បរិស្ថាន សិក្សាលំអិតបន្ថែមទៀត និងមានការចូលរួមផ្តល់យោបល់ច្រើនកាន់តែ ល្អ ជាពិសេសប្រជាពលរដ្ឋ អាជ្ញាធរមូលដ្ឋាន អង្គភាព ស្ថាប័ន ក្រសួង និងអង្គការពាក់ព័ន្ធនានា ។ | ៣ | ក្រុមហ៊ុនត្រូវសហការធ្វើសិក្ខាសាលា ដើម្បីធ្វើការពិភាក្សាឱ្យបានលំអិត និងទំទួលយកយោបល់ជាសាធារណៈ យកមកធ្វើការវិភាគ ដើម្បីឱ្យគំរោងនេះដំណើរការបានល្អប្រសើរ ។ |
| សូមឱ្យក្រុមហ៊ុន សាងសង់រាល់ហេដ្ឋារចនាសម្ព័ន្ធ ដោយផ្អែកទៅបទដ្ឋានបច្ចេកទេស និងកំណត់ឱ្យច្បាស់នូវគុណភាព និងសុវត្ថិភាពសំណង់ ដើម្បីជៀសវាងគ្រោះថ្នាក់ជាជាយថាហេតុណា មួយដល់ប្រជាពលរដ្ឋ ។ | ១២ | ក្រុមហ៊ុនត្រូវធានាគុណភាពសំណង់ និង ខិតខំព្យាយាមធ្វើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនី ឱ្យបានរួចរាល់ទៅតាមកាលកំណត់ និងតាមស្តង់ដាបច្ចេកទេស ជៀសវាងគ្រោះថ្នាក់ជាយថាហេតុណាមួយ ដល់ប្រជាពលរដ្ឋ ។ |
| សូមឱ្យមានការជួសជុលហេដ្ឋារចនាសម្ព័ន្ធគំរោងឱ្យ បានរឹងមាំឡើងវិញមុនពេលប្រគល់គំរោងនេះ ទៅឱ្យរាជរដ្ឋាភិបាលកម្ពុជា គ្រប់គ្រងបន្ត ។ | ៤ | ក្រុមហ៊ុនត្រូវមានផែនការជួសជុលហេដ្ឋារចនាសម្ព័ន្ធគំរោងតាមកាលកំណត់នៃគុណភាពសំណង់ ។ម្យ៉ាងទៀត ក្រុមហ៊ុនត្រូវជួសជុលហេដ្ឋារចនាសម្ព័ន្ធគំរោងឡើងវិញ ឱ្យបានរឹងមាំមុន នឹងប្រគល់គំរោងនេះ ទៅឱ្យរាជរដ្ឋាភិបាលគ្រប់គ្រង បន្តដោយសុវត្ថិភាព ។ |
| សូមឱ្យក្រុមហ៊ុនវិនិយោគ ឧបត្ថម្ភដល់មន្ត្រីបរិស្ថានខេត្ត ចំនួន ៥-១០នាក់ ក្នុងការល្បាតការពារព្រៃឈើជុំវិញតំបន់គំរោង ។ | ៤ | ក្រុមហ៊ុនត្រូវកំណត់ថវិកាសំរាប់កិច្ចការពារ និងអភិរក្សធនធានធម្មជាតិក្នុង និងជុំវិញតំបន់គំរោង នេះ ទៅក្នុងកញ្ចប់ថវិកា ស្តីពី ផែនការគ្រប់គ្រងបរិស្ថាន របស់គំរោង ។ |
| សូមឱ្យក្រុមហ៊ុនជួយលើការងារបណ្តុះបណ្តាលមន្ត្រីជំនាញ ផ្នែកគ្រប់គ្រងប្រព័ន្ធវារីអគ្គីសនី និងវិស្វកម្មសំណង់វារីអគ្គិសនី នេះផង ដើម្បីធ្វើឱ្យប្រទេសកម្ពុជាយើង មានធនធានមនុស្ស លើផ្នែកនេះពិតប្រាកដ ហើយនឹងអាចបន្តវេនពីក្រុមហ៊ុននៅ ពេលក្រុមហ៊ុន បញ្ចប់អាណត្តិ ។ | ៥ | ក្រុមហ៊ុនត្រូវមានផែនការបណ្តុះបណ្តាលមន្ត្រីក្នុងក្រសួង និងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពត លើផ្នែកគ្រប់គ្រងនិងបច្ចេកទេសវារីអគ្គិសនីនេះ និងគំរោងចំណាយផងដែរ ។ |
| សូមឱ្យក្រុមហ៊ុនវិនិយោគវារីអគ្គិសនីនេះផ្តល់ឱ្យមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលនូវឯកសារភូគព្ភសាស្ត្រ និងរ៉ែ ដែលបានសិក្សានៅតំបន់គំរោងនេះផង ។ | ៤ | ក្រុមហ៊ុនត្រូវផ្តល់ឯកសារភូគព្ភសាស្ត្រ និងរ៉ែ ទៅឱ្យក្រសួង និងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពត ក្រោយពីធ្វើការវិភាគដី ក្នុងតំបន់គំរោង នៅប្រទេសចិនរួចរាល់ ។ |
| សូមឱ្យក្រុមហ៊ុនត្រៀមថវិកាសំរាប់គណៈកម្មការជាតិក្នុងការត្រួតពិនិត្យនិងឃ្លាំមើលបរិស្ថានក្នុងដំណើរការប្រតិបត្តិ និងថែទាំ របស់គំរោង ។ | ៥៥ | ក្រុមហ៊ុនត្រូវកំណត់ថវិកាសំរាប់គណៈកម្មការជាតិក្នុងការត្រួតពិនិត្យនិងឃ្លាំមើលបរិស្ថាននេះ ទៅក្នុងកញ្ចប់ថវិកា ស្តីពី ផែនការគ្រប់គ្រង បរិស្ថាន របស់គំរោង ។ |
| សូមឱ្យក្រុមហ៊ុនជួយថែរក្សាព្រៃឈើ នៅជុំវិញតំបន់គំរោង កុំបាត់បង់ បើមិនដូច្នេះទេ ច្បាស់ជាខ្វះប្រភពទឹក សំរាប់ ដំណើរការផលិតថាមពលវារីអគ្គិសនីនេះហើយ ។ | ១២ | ក្រុមហ៊ុនត្រូវសហការជាមួយគណៈកម្មការត្រួតពិនិត្យបរិស្ថានស្ថាប័នជំនាញ និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីថែរក្សាព្រៃឈើ នៅជុំវិញតំបន់គំរោង នេះ និងមានគំរោងចំណាយផងដែរ ។ |
| សូមឱ្យក្រុមការងារ ទទួលយកមន្ត្រីឧទ្យានម្នាក់ ឬ២នាក់ នាំផ្លូវ និងបង្កើនចំណេះដឹងលើការងារវាយតំលៃហេតុប៉ះពាល់ បរិស្ថាន | ៣ | ក្រុមការងារSAWAC ត្រូវទទួលយកមន្ត្រីឧទ្យានជាតិមុន្និវង្សបូកគោ២រូប ដើម្បីចូលរួមការងារ ដើម្បីឱ្យដំណើរការវាយ |

Draft

| | | |
|---|---|---|
| នេះផង ។ | | តំលៃ នេះ ល្អប្រសើរ ។ម្យ៉ាងទៀតក្រុមការងារ SAWAC ត្រូវស្នើសុំធ្វើស្លាកសំគាល់ដល់មន្ត្រីឧទ្យានជាតិ ដើម្បីឱ្យក្រុមហ៊ុន Sinohydro ទទួលស្គាល់ និង ងាយស្រួលក្នុងការចេញ-ចូល ក្នុងតំបន់គំរោង ។ |
| ការប៉ះពាល់ដីស្រែ និងដើមឈើហូបផ្លែ ដោយសារ ការសាងសង់ប្រព័ន្ធខ្សែចំលង នៅភូមិមាត់ពាម(ឃុំម៉ាក់ប្រាង) ភូមិអណ្តូងជីម៉ឺន ភូមិបាក់ប្រាង និងកំពង់ក្រែង (ឃុំកំពង់ក្រែង) និងភូមិព្រៃ ឃុំ (ឃុំព្រៃឃ្មុំ) ស្រុក ទឹកឈូ ខេត្តកំពត សំណូមពរឱ្យក្រុមហ៊ុន ដោះស្រាយសំណង សមស្រប ។ | ៣៥ | ក្រុមហ៊ុននឹងសិក្សាដំណោះស្រាយសំណងនេះជូនប្រជាពលរដ្ឋនិងសហការ ជាមួយក្រសួង និងមន្ទីរជំនាញព្រមទាំងអាជ្ញាធរមូលដ្ឋាន ដើម្បីធ្វើការ សំរបសំរួលតាមការកំណត់ជាក់ស្តែង និងមិនលំអៀង ។ |
| សូមឱ្យក្រុមហ៊ុនសាងសង់ប្រព័ន្ធខ្សែបណ្តាញអគ្គិសនីត្រូវតាមស្តង់ដាបច្ចេកទេស របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល កំណត់ ។ | ៤៥ | ក្រុមហ៊ុនត្រូវអនុវត្តន៍ ឱ្យបានត្រឹមត្រូវតាមស្តង់ដាក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងតាមបទដ្ឋានបច្ចេកទេស ដើម្បីការពារសុវត្ថិភាព សាធារណៈ ។ |
| សូមឱ្យក្រុមហ៊ុនដាក់ស្លាកសញ្ញាសំគាល់គ្រោះថ្នាក់ ជាប់ទៅនឹងបង្គោលភ្លើង ហើយត្រូវមានប្រព័ន្ធផ្តាច់ចរន្តភ្លើងស្វ័យ ប្រវត្តិនៅពេលមានហេតុការណ៍ទុស្សេ ឬដាច់ខ្សែភ្លើងម្តងៗ ។ | ៥៥ | ក្រុមហ៊ុនត្រូវមានផែនការបំពាក់ស្លាកសញ្ញាសំគាល់គ្រោះថ្នាក់ជាអក្សរខ្មែរជាប់នឹង បង្គោលភ្លើង និងមានប្រព័ន្ធផ្តាច់ចរន្តស្វ័យប្រវត្តិ នៅពេលមានហេតុការណ៍ទុស្សេ ឬដាច់ខ្សែចំលងអគ្គិសនី កើតឡើង ។ |
| សូមឱ្យក្រុមហ៊ុនជួសជុលផ្លូវដឹកថ្ម ទៅកាន់តំបន់គំរោង ឱ្យមានលក្ខណៈស្មើល្អ ឡើងវិញ នៅពេលបញ្ចប់ការងារដឹកថ្មនេះ និងដាក់លូនៅចំណុចអូរអន្លង់ក្រញូង នៅភូមិអណ្តូងជីម៉ឺន ដើម្បីរំដោះទឹកជំនន់ នៅរដូវវស្សា ។ | ៥៦ | ក្រុមហ៊ុនត្រូវជួសជុលផ្លូវដឹកថ្ម នេះឡើងវិញ ដើម្បីសំរួលដល់ការធ្វើចរាចររបស់ប្រជាពលរដ្ឋ ឱ្យបានឆាប់រហ័ស ហើយនឹងសហការជាមួយ មន្ទីរជំនាញខេត្ត ក្នុងការដាក់លូនៅចំណុចអូរអន្លង់ក្រញូងក្នុងភូមិសាស្រ្ត ភូមិអណ្តូងជីម៉ឺន ។ |
| ក្រុមហ៊ុនត្រូវផ្សព្វផ្សាយអំពីសុវត្ថិភាពនៃប្រព័ន្ធខ្សែចំលងនេះ ។ | ១៥ | ក្រុមហ៊ុនត្រូវសហការជាមួយក្រសួង និងមន្ទីរជំនាញ ក្នុងការផ្សព្វផ្សាយ អំពីសុវត្ថិភាពនៃប្រព័ន្ធខ្សែចំលងនេះ |
| សូមឱ្យក្រុមហ៊ុន ឬអាជ្ញាធរអគ្គិសនីកម្ពុជា តបណ្តាញអគ្គិសនីឱ្យប្រជាពលរដ្ឋរស់តាមគន្លងខ្សែចំលងតង់ស្យុងខ្ពស់នេះ មានអគ្គិសនី ប្រើប្រាស់ និងតំលៃថោក ។ | ៦៥ | ក្រុមហ៊ុនត្រូវសហការជាមួយក្រសួង និងមន្ទីរជំនាញ ក្នុងការតបណ្តាញអគ្គិសនី ឱ្យប្រជាពលរដ្ឋបានប្រើប្រាស់ ទៅតាមតំលៃ ដែលរដ្ឋកំណត់ ។ |

## ៦.៥ របាយការណ៍សង្ខេប នៃសិក្ខាសាលា ស្តីពី " ការចូលរួមវាយតំលៃលទ្ធផលសិក្សាហេតុប៉ះពាល់បរិស្ថានលើគំរោង វារីអគ្គិសនីកំចាយ "

នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ នៅសណ្ឋាគារ កំពតឪយ៉ាម៉ង់ មានបើកសិក្ខាសាលា ស្តីពី " ការចូលរួមវាយតម្លៃលទ្ធផលសិក្សាហេតុប៉ះពាល់បរិស្ថាន លើគំរោងវារីអគ្គិសនីកំចាយ " ក្រោមអធិបតី ឯកឧត្តម ហេង វុត្ថា អភិបាលរង ខេត្តកំពត សមាសភាពចូល រួម ដូចមានភ្ជាប់ក្នុងបញ្ជីអវត្តមាន នៅឧបសម្ព័ន្ធ ៤ ។

កិច្ចចាប់ផ្តើមសិក្ខាសាលា :

- ការថ្លែងសន្ទរកថា បើកសិក្ខាសារបស់ឯកឧត្តម ហេង វុត្ថា អភិបាលរង ខេត្តកំពត ។

Draft

- របាយការណ៍សង្ខេបរបស់តំណាងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តកំពត ស្តីពី កិច្ចសហការរវាងមន្ទីរ និងក្រុមហ៊ុន Sinohydro ។
- របាយការណ៍សង្ខេប របស់លោក ទិត សារ៉ា តំណាងក្រុមការងារ Sawac ស្តីពី សកម្មភាពសិក្សាគំរោងវារីអគ្គិសនីកំចាយ ។

**សកម្មភាពសិក្ខាសាលាសង្ខេប :**

- ការធ្វើបទបង្ហាញរបស់លោក សួ ឈាងយូ ស្តីពី លទ្ធផលសិក្សាហេតុប៉ះពាល់បរិស្ថានរូបសាស្ត្រ និងធនធានព្រៃឈើក្នុងតំបន់គំរោង ។
- ការធ្វើបទបង្ហាញរបស់លោក ទិត សារ៉ា ស្តីពី លទ្ធផលសិក្សាហេតុប៉ះពាល់បរិស្ថានជីវសាស្ត្រ ដោយសារគំរោងវារីអគ្គិសនីកំចាយ ។
- ការធ្វើបទបង្ហាញរបស់លោក ម៉ុក ឆាយា ស្តីពី លទ្ធផលសិក្សាហេតុប៉ះពាល់បរិស្ថានសេដ្ឋកិច្ច-សង្គម ដោយសារគំរោងវារីអគ្គិសនី កំចាយ ។

**លទ្ធផល សិក្ខាសាលា :**

- មានការគាំទ្រគំរោងនេះ ១០០ភាគរយ ព្រោះថា គំរោងនេះ មានការចំណាយលើការប៉ះពាល់តិចតួច និងទទួលផលចំណេញច្រើន។
- សំណើសុំឱ្យមានការធ្វើអាងប្រព្រឹត្តិកម្មទឹក សំអាតកាកសំណល់ចេញពីការដ្ឋានលាងថ្ម និងស៊ីម៉ង់តិ៍ ត្រូវបានក្រុមការងារបញ្ជាក់ថា ក្រុមហ៊ុនបានធ្វើអាងស្តុកទឹកលាងថ្ម និងកាកសំណល់ស៊ីម៉ង់តិ៍ និងប្រឡាយបង្ហូរទឹករងកករសំណល់នេះ តាំងពីឆ្នាំ២០០៧ មកម្ល៉េះ តែអាងនេះត្រូវពេញពេលមានភ្លៀង ដូចនេះ នៅរដូវភ្លៀងម្តងៗ អាចមានការហៀរនូវកាកសំណល់ដែលមិនទាន់រងកករ នេះខ្លះដែរ សូមអធ្យាស្រ័យ ។
- ចំពោះសំនួរសួរថា ទីតាំងស្នាក់នៅរបស់បុគ្គលិក-កម្មករ ក្រុមហ៊ុនមានធ្វើបង្គន់ និងអាងចំរោះទឹកកខ្វក់ ដែរឬទេ ? សំនួរនេះ ត្រូវបានបញ្ជាក់ថា ក្រុមហ៊ុនបានធ្វើបង្គន់ និងអាងចំរោះទឹកកខ្វក់រួចហើយដែរ តាំងពីឆ្នាំ២០០៧ មកម្ល៉េះ ។
- ចំពោះ សំនួរសួរថា កំរិត Phទាប នៅស្ទឹងកំចាយ ក្នុងតំបន់គំរោង តើក្រុមហ៊ុនត្រូវកែតាមវិធីសាស្ត្រណា ? ចំលើយឆ្លើយថា ការសាងសង់គំរោង មានទ្រង់ទ្រាយធំណាស់ ដូចនេះសារធាតុគីមី ដែលចេញពី សំភារៈសំណង់ នឹងធ្វើឱ្យទឹកក្នុងស្ទឹង ថយចុះ គុណភាព ជាក់ជាមិនខាន ចំពោះការកែលំអក្នុងដំណាក់កាលសាងសង់គឺក្រុមហ៊ុនបានធ្វើអាងស្តុកកាកសំណល់ដូចរៀបរាប់ រួចហើយតែមិនអាចចំរោះកករនៃកាកសំណល់ទាំងអស់បានទេ គឺបានត្រឹមតែកាត់បន្ថយប៉ុណ្ណោះ។ ម្យ៉ាងទៀត ការលំបាកនេះ គឺយើងនឹងរងចាំក្រោយពេលសាងសង់ រយៈពេល២-៣ឆ្នាំ សមាសធាតុគីមីគ្រប់ប្រភេទ ដែលរលាយក្នុងទឹកនឹងមានលំនឹង ឡើងវិញ នោះកំរិត Ph ក៏អាចកើនឡើងវិញដែរ ។
- ម្យ៉ាងទៀត ការខ្វះអុកស៊ីសែន ធ្វើឱ្យទឹកមានគុណភាពមិនល្អប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ គឺ យើងអាចប្រើម៉ូទ័របំបែក ម៉ូលេគុលទឹក ឱ្យមានអុកស៊ីសែន ការពារកុំឱ្យទឹកស្អុយ ចូលដល់ស្ថានីយ៍រដ្ឋាករទឹកខេត្តកំពតឡើយ ។

Draft

- ចំពោះ ការប៉ះពាល់ដល់ការធ្វើចរាចរត្រី ក្រុមហ៊ុនបានឯកភាព និងមានផែនការទប់ទំនប់ទឹកប្រៃនៅខាងក្រោមស្ថានីយរដ្ឋាករ ទឹកខេត្តកំពត សព្វថ្ងៃនេះ ដើម្បីធ្វើការអភិរក្សត្រីមេពូជដែលអាចរស់នៅផ្នែកខាងក្រោមទំនប់ទី២ មកដល់ស្ថានីយរដ្ឋាករទឹក នេះ តាមសំណើរហើយ។
- ចំពោះសំណើសុំកូនត្រីប្រលែងក្នុងធម្មជាតិ ក្នុង១ឆ្នាំ ១០០.០០០ ក្បាលនោះ ក្រុមហ៊ុននឹងយកសំណើនេះ ទៅពិភាក្សាជាមួយថ្នាក់ដឹកនាំក្រុមហ៊ុន ។
- ចំពោះទឹកជំនន់ខ្លាំង ក្រុមហ៊ុននឹងបង្ហៀរចេញតាមប្រឡាយដោះទឹក និងតាមទំនប់បង្ហៀរមិនឱ្យបាក់ទំនប់ធ្វើឱ្យលិចនៅឯភូមិប្រជាពលរដ្ឋលិចលុងលើយ (ចំលើយរបស់តំណាងក្រុមហ៊ុន)
- ការប៉ះពាល់មុខរបររកផលអនុផលព្រៃឈើ ឯកភាពឱ្យមានការបង្កើតជាសហគមន៍ដាំឬស្សី-ផ្តៅ នៅតាមជើងភ្នំកំចាយ ។
- ក្រុមហ៊ុនបានមានយោបល់ថា ការប៉ះពាល់លើជីវភាពប្រជាពលរដ្ឋ គឺក្រុមហ៊ុននឹងខិតខំធ្វើតាមសំណូមពរទាំងអស់ ដូចជាកន្លងមក ក្រុមហ៊ុនបានធ្វើផ្លូវ ផ្តល់ការងារឱ្យធ្វើជូនប្រជាពលរដ្ឋ បន្ទាប់មកក្រុមហ៊ុនប្រជាពលរដ្ឋនឹងមានភ្លើងប្រើប្រាស់ដោយតំលៃសមរម្យសហការការពារព្រៃឈើ និងសត្វព្រៃជុំវិញតំបន់គំរោងសហការធ្វើទំនប់ការពារទឹកប្រៃក្នុងគោលបំណង អភិរក្សត្រីមេពូជ និងផ្តល់ទឹកសំរាប់ដំណាំរបស់ប្រជាពលរដ្ឋ និងពង្រីកតំបន់ទេសចរណ៍បន្ថែមទៀត ។ នៅពេលល្ងាចជាកម្មវិធីពិភាក្សាតាមក្រុម លទ្ធផលដូចខាងក្រោម :

**លទ្ធផលពិភាក្សាក្រុមទី១ :**

| បរិយាយ | កំណត់ចំពេលការប៉ះពាល់បរិស្ថាន | វិធានការកាត់បន្ថយ |
|---|---|---|
| ១ បញ្ហាហូរច្រោះដី<br>ទឹកកខ្វក់ | ពេលសាងសង់ ខ្លាំង | - ធ្វើអាងសំអាតទឹក មុនបង្ហូរចូលស្ទឹង<br>- ធ្វើជញ្ជាំងការពារកុំឱ្យបាក់ដី |
| ២- ប្រព័ន្ធជលសាស្ត្រ (ទឹកលើដី)<br>ទឹកហូរខុសពីស្ថានភាពដើម | ពេលសាងសង់ខ្លាំង | ផ្នែកខាងក្រោមទំនប់ទី២ កាយឱ្យទឹកហូរចុះមកកន្លែងកំសាន្ត ទឹកឈូ ដូចធម្មតា ។ |
| ៣- ការបំពុលខ្យល់<br>ការហុយធូលីបណ្តាលមកពីការដឹកជញ្ជូន | ពេលសាងសង់មធ្យម | ស្រោចទឹកជាប្រចាំ នៅទីប្រជុំជន ក្នុង១ថ្ងៃ ចំនួនពី២-៣ដង |
| ៤- ការបាត់បង់ មច្ឆជាតិ | ពេលសាងសង់មធ្យម | - បង្កើនអាងអភិរក្សពូជត្រី នៅផ្នែកខាងក្រោមទំនប់ទី២ ក្រោយស្ថានីយ បូមទឹកខេត្តកំពត បន្តិច ។<br>- ផ្តល់កូនត្រីពូជក្នុងស្រុក ព្រលែងក្នុងព្រែក និងស្ទឹង ដើម្បីធ្វើត្រី ដែលបាត់បង់មានកំណើនឡើងវិញ ។ |
| ៥- ការបាត់បង់សត្វព្រៃ | ពេលសាងសង់ខ្លាំង | - ថែរក្សាព្រៃឈើជុំវិញតំបន់គំរោង ។ |
| ៦- ហានិភ័យ<br>ការបង្ហូរទឹកពេលមានទឹកជំនន់ ឬមានទឹកស្តុកក្នុងអាងហួសកំរិត | ក្រោយពេលសាងសង់មធ្យម | - ផ្តល់ដំនឹងតាមវិទ្យុ ទូរទស្សន៍ មុនមានការបង្ហូរទឹកម្តងៗ<br>- ត្រៀមសំភារៈ និងមធ្យោបាយសង្គ្រោះ (ទូក-កាណូត អាវពោង) ។ |

Draft

## លទ្ធផលពិភាក្សាក្រុមទី២ :

| បរិយាយ | កំណត់ទំហំនៃការប៉ះពាល់បរិស្ថាន | វិធានការកាត់បន្ថយ |
|---|---|---|
| **១- ធនធានរូបសាស្ត្រ** | - ពេលសាងសង់ និងក្រោយពេលសាងសង់មធ្យម | - ដាំស្មៅ និងដើមឈើឡើងវិញ |
| - បាត់បង់លក្ខណៈធម្មជាតិ | | - ធ្វើរនាំងបេតុង តាមជំរាលភ្នំ នៃអាងទឹក |
| - ធ្វើឱ្យបាក់ដី | - ពេលសាងសង់ខ្លាំង | - ប្រើឧបករណ៍បំបែកទឹក បង្កើនអុកស៊ីសែន |
| - ទឹកកខ្វក់ | - ពេលសាងសង់ខ្លាំង | - ស្រោចទឹក |
| - ដីហុយតាមដងផ្លូវ | - ពេលសាងសង់ខ្លាំង | - ធ្វើអាងប្រព្រឹត្តិកម្មទឹក |
| - ទឹកល្អក់ | - ពេលសាងសង់ខ្លាំង | - ធ្វើឃ្លាំងសំភារៈ តាមបទដ្ឋានបច្ចេកទេស និងការពារបរិស្ថាន |
| - ដីស្អុយ | - ពេលសាងសង់ខ្លាំង | - ដាក់រំសេវផ្ទុះដែលអាចធ្វើឱ្យថ្មខ្ទាតចេញមិនឱ្យលើសពី១០០ម |
| - ប៉ះពាល់អារម្មណ៍ និងសុខភាព | - ពេលសាងសង់ខ្លាំង | - ការបំផ្ទុះថ្ម ត្រូវធ្វើសកម្មភាព នៅពេលម៉ោងការងារ កុំធ្វើនៅពេលសំរាក របស់ប្រជាពលរដ្ឋ ។ |
| **២- ធនធានជីវសាស្ត្រ** | | |
| - បាត់បង់ពូជត្រីមួយចំនួន | - ក្រោយពេលសាងសង់មធ្យម ពេលសាងសង់ខ្លាំង ។ | - ធ្វើទំនប់នៅផ្នែកខាងក្រោមទំនប់ទី២ ត្រង់ចំណុចក្រោយស្ថានីយវដ្តករទឹក ខេត្តកំពត ។ |
| - បាត់បង់ធនធានព្រៃឈើ | - ក្រោយពេលសាងសង់មធ្យម ពេលសាងសង់ ខ្លាំង | - លែងកូនត្រី |
| - បាត់បង់ជំរក | | - ដាំដើមឈើបន្ថែមថែមទៀត |
| - បាត់បង់ដីឧទ្យានជាតិ | - ក្រោយពេលសាងសង់ និងកំពុងសាងសង់តិចតួច | - ថែទាំព្រៃឈើដែលនៅសល់ |
| | | - ហាមប្រមាញ់ |
| | | - ត្រូវមានមូលនិធិសំរាប់ការពារសត្វព្រៃ និងឧបត្ថម្ភដល់មន្ត្រីឧទ្យានជាតិដើម្បីធ្វើការល្បាត និងការពារសត្វព្រៃ ។ |
| **៣- ធនធានសេដ្ឋកិច្ច-សង្គម** | | |
| - ការបង្កបង្កើនផលដំណាំចំការឆ្នាំ២០១០ ពុំបានផល ។ | - ពេលសាងសង់ខ្លាំង | - ផ្តល់គោលនយោបាយដីធ្លី ដល់អ្នកប៉ះពាល់ ដោយគំរោងនេះ តាមតំបន់ ដោយមានការយល់ព្រមទាំងសងខាង (ប្រជាពលរដ្ឋ និងប្រជាពលរដ្ឋ) ដីភ្នំគិតតែជំនាំ ចំណែកដីចំការ គិតទាំងដំណាំ និងដី ។ |
| - ប្តូរទីតាំងលំនៅដ្ឋាននៅពេលប៉ះពាល់ជាមួយគន្លងខ្សែបណ្តាញវារីអគ្គិសនី | - ពេលសាងសង់ខ្លាំង | ជួលដីនៅតំបន់បំបែកថ្ម រយៈពេល៤-៥ឆ្នាំ ។ |
| - ប្រកបមុខរបរមិនពេញលេញ | - ពេលសាងសង់ខ្លាំង | |
| - ខូចគុណភាពទឹកធ្វើឱ្យប៉ះពាល់ដល់សុខភាព | - ពេលសាងសង់ខ្លាំង<br>- ពេលសាងសង់ខ្លាំង | - បណ្តុះបណ្តាញ បង្កើតការងារធ្វើ សាងសង់ស្ថានីយបូមទឹកថ្មី ផ្គត់ផ្គង់ទឹកស្អាត ដោយយកទឹកពីតំបន់ខាងលើទំនប់ទី២ ។ |
| - មានការថយចុះចំនួនទេសចរណ៍ | - ពេលសាងសង់ខ្លាំង | |
| - ការដឹកជញ្ជូនថ្ម ធ្វើឱ្យប៉ះពាល់ដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ ។ | - ពេលសាងសង់ខ្លាំង | - ថែរក្សាព្រៃឈើ និងស្ថានដី ឱ្យមានសោភ័ណ ។<br>- ស្រោចទឹក ពាក់ម៉ាស់ និងជួសជុលផ្លូវឡើងវិញក្រោយពី បញ្ចប់គំរោង ។ |
| - បាត់បង់សំរស់ធម្មជាតិ | - ពេលសាងសង់ខ្លាំង | - ដាំដើមឈើឡើងវិញ ។ |
| - ការដឹកជញ្ជូនថ្មធ្វើឱ្យប្រជាពលរដ្ឋពិបាកធ្វើដំណើរ | - ក្រោយពេលសាងសង់ខ្លាំង | - ត្រូវមានការធានាសុវត្ថិភាពដល់ប្រជាពលរដ្ឋ ដោយមានជា ការបន្លឺសំឡេងស៊ីរ៉ែន មានការត្រួតពិនិត្យស្ថានភាពទំនប់ ជាប្រចាំ អាវពោងមធ្យោយសង្គ្រោះ ។ |
| - ហានិភ័យ (អាចទឹកជំនន់ធ្វើឱ្យបាក់ទំនប់) | | - ត្រូវធានាជីវិតរបស់កម្មករគំរោង |
| | | - រាជរដ្ឋាភិបាលត្រូវចូលរួមចំណែក ក្នុងការពារសុវត្ថិភាពនេះ ដែរ ។ |

Draft

## លទ្ធផលពិភាក្សាក្រុមទី៣ :

| បរិយាយ | កំណត់ចំណាំនៃការប៉ះពាល់បរិស្ថាន | វិធានការកាត់បន្ថយ |
|---|---|---|
| **១- ធនធានរូបសាស្ត្រ** | | |
| - ប្រព័ន្ធជលសាស្ត្រទឹកលើដី<br>ទឹកកខ្វក់ : ការលាងថ្ម និងល្បាយបេតុងហូរចូលប្រព័ន្ធទឹក | - ក្រោយពេលសាងសង់តិច<br>- ពេលសាងសង់ខ្លាំង | |
| - ការរាំងស្ទះចរន្តទឹកហូរចុះមកតំបន់ខាងក្រោម ។ | - ក្រោយពេលសាងសង់ខ្លាំង<br>- ពេលសាងសង់មធ្យម | - រៀបចំប្រព័ន្ធបង្ហូរទឹកឱ្យបានសមស្រប |
| - ការហូរច្រោះ និងគុណភាពដី<br>ការហូរច្រោះពេលជីក និងឈូសឆាយដី | - ពេលសាងសង់ខ្លាំង<br>- ក្រោយពេលសាងសង់តិច | - ដាំស្មៅ និងដើមឈើតាមជើងទេរ និងរៀបបេតុងទប់ ។ |
| - ការបំពុលខ្យល់ :<br>ការហុយដី ធូលី ពេលដឹកជញ្ជូន និងពេលបំបែកថ្ម ។ | | - គ្របគង់នៅពេលដឹក និងស្រោចទឹកផ្លូវ<br>- ត្រូវបាញ់បំបែកថ្មនៅពេលរដូវភ្លៀង |
| - ការបំពុលទឹក<br>ដោយសារលាងថ្ម ឈូសឆាយពង្រាបដី និងបង្ហូរទឹកស៊ីម៉ងតិ៍ កាកសំណល់ចេញពីកន្លែងស្នាក់នៅ និងសំរាម ។ | - ពេលសាងសង់ខ្លាំង | - មានប្រឡាយបង្ហូរទឹកនិងធ្វើអាងចំរោះទឹកស៊ីម៉ងតិ៍<br>- មានធុងសំរាម និងរថយន្តដឹកសំរាម<br>- មានបង្គន់ដែលមានអាងប្រព្រឹត្តិកម្មទឹក |
| - ការបំពុលដី : ដីដាំដំណាំ ដែលប្រើប្រាស់ទឹកកខ្វក់ ខូចគុណភាពដី ធ្វើឱ្យដំណាំងាប់ ។ | - ពេលសាងសង់ខ្លាំង | - ជីកស្រះទឹក ឬជីកអណ្តូងតាមគ្រួសារ/ចំការ |
| **២- ធនធានជីវសាស្ត្រ** | | |
| - ទឹកពុលធ្វើត្រីងាប់ | - ក្រោយពេលសាងសង់ និងពេលសាងសង់ខ្លាំង ។ | |
| - បាត់បង់ជំរកបន្តពូជរបស់ត្រី<br>- ការរាំងស្ទះចរាចរត្រី ដោយទំនប់<br>- អាចធ្វើឱ្យបាត់បង់ប្រភេទត្រី១ចំនួន | - ក្រោយពេលសាងសង់ និងពេលសាងសង់ ខ្លាំង | - ធ្វើទំនប់នៅផ្នែកខាងក្រោមទំនប់ទី២ត្រង់ចំណុចក្រោយស្ថានីយរដ្ឋករទឹក ខេត្តកំពត ដើម្បីអភិរក្សពូជត្រី ។<br>- លែងកូនត្រី និងសង់ស្ថានីយភ្ញាស់កូនត្រីពូជ |
| - បាត់បង់ជំរកសត្វព្រៃ ដោយសារបាត់បង់ព្រៃឈើ | - ក្រោយពេលសាងសង់ និងកំពុងសាងសង់ខ្លាំង<br>- កំពុងសាងសង់ខ្លាំង | - ដាំដើមឈើបន្ថែមថែមទៀត<br>- ថែទាំ និងការពារជំរកសត្វព្រៃ |
| **៣- ធនធានសេដ្ឋកិច្ច-សង្គម** | | |
| - ការបាត់បង់មុខរបររុករកអនុផល ព្រៃឈើ ។ | - ពេលសាងសង់ខ្លាំង | - បណ្តុះបណ្តាល បង្កើតមុខរបរ រៀបចំសហគមន៍ដាំឬស្សី ឬផ្តៅ |
| - ប្រាក់ចំណូលទេសចរណ៍ទឹកឈូថយចុះដោយសារ គុណភាពទឹក និងបរិមាណ ទឹកថយចុះ | - ពេលសាងសង់ខ្លាំង | - រៀបចំពង្រីកតំបន់ទេសចរបន្ថែម ដោយផ្តល់ឱ្យអ្នកដែលរងការប៉ះពាល់ ជាអាទិភាព |
| - នឹងធ្វើឱ្យប៉ះពាល់ដល់សុខភាពប្រជា ពលរដ្ឋ ដោយសារ ការប្រើប្រាស់ទឹក មិនស្អាត ក្នុងដំណាក់កាលសាងសង់ និងក្រោយសាងសង់គំរោង ។ | - ក្រោយពេលសាងសង់ដំបូង និងកំពុងសាងសង់ ខ្លាំង ។ | - ត្រូវរកកន្លែងសមស្របមួយ សាងសង់ស្ថានីយ៍បូមទឹកថ្មីមួយ ក្បែរទំនប់វារីអគ្គិសនី ។ |

## ការពិភាក្សាអំពីតំលៃបរិស្ថាន ដែលត្រូវបានប៉ះពាល់ដោយគំរោង :

[redacted]

## ការវាយតំលៃលើសិក្ខាសាលា

ថ្ងៃទី .ខែ. ឆ្នាំ : ២៥-មីនា - ២០១១

ចំនួនសរុប: ២៧នាក់ បានចូលរួមវាយតំលៃ

គំរោង : វារីអគ្គិសនីកំចាយ

### ការវាយតំលៃទូទៅលើសិក្ខាសាលា

តើអ្នកមានការពេញចិត្តយ៉ាងណាដែរ? ចំពោះ:

១- ដំណើរការនៃសិក្ខាសាលា?

ពេញចិត្តខ្លាំង: ២២នាក់ ពេញចិត្ត : ៥នាក់ ល្មម : 0 មិនពេញចិត្ត: 0 មិនពេញចិត្តសោះ 0

២- តើសិក្ខាសាលានេះបានឆ្លុះបញ្ចាំងពីការវាយតំលៃហេតុប៉ះពាល់បរិស្ថានលើគំរោងវារីអគ្គិសនីកំចាយ ដែរ រឺទេ?

បាទ / ចាស : ២៧នាក់ ទេ : 0នាក់

៣- តើពេលវេលាដែលបានរៀបចំសិក្ខាសាលាគ្រប់គ្រាន់ រឺទេ?

គ្រប់គ្រាន់ : ២០នាក់ មិនគ្រប់គ្រាន់ : ០៦នាក់

### ខ្លឹមសារនៃសិក្ខាសាលា

៤-តើអ្នកមានការពេញចិត្តយ៉ាងណាចំពោះវិធីសាស្ត្រ និងលទ្ធផលសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន?

ពេញចិត្តខ្លាំង: ១១នាក់ ពេញចិត្ត : ១៥នាក់ ល្មម : ០១នាក់ មិនពេញចិត្ត: 0 មិនពេញចិត្តសោះ 0

Draft

៥- តើអ្នកយល់យ៉ាងណាចំពោះ បទបង្ហាញក្នុងសិក្ខាសាលានេះ?

ល្អណាស់ : ១៣នាក់ ល្អបង្គួរ : ១៤នាក់ មធ្យម: 0 មិនល្អ: 0

៦- តើអ្នកទទួលបានអ្វីខ្លះពីសិក្ខាសាលានេះ?

- យល់ច្បាស់ពីព័ត៌មានពីការសាងសង់វារីអគ្គិសនី ។
- បានយោបល់នឹងគំនិតថ្មីៗពីអង្គសិក្ខាសាលានេះ ។
- បានយល់ដឹងកាន់តែច្រើនអំពីផលវិជ្ជមាន និងអវិជ្ជមានដែលទទួលបានពីទំនប់វារី អគ្គិសនីកំចាយចំពោះ ប្រជាជនសហគមន៍ មូលដ្ឋានពិសេសទៅលើធនធានធម្មជាតិ ។
- ទទួលបានការយល់ដឹងពីវិធីសាស្ត្រល្អៗនៃការធ្វើ EIA, យល់ដឹងពីការយកចិត្ត ទុកដាក់ និងរបៀបធ្វើការ របស់មន្ត្រីរដ្ឋាភិបាលនានាក្នុងការជជែកវែកញែកពីការ ដោះស្រាយដែលល្អ ។
- បានទទួលការយល់ដឹងអំពីការសាងសង់នេះ មានការប៉ះពាល់ រីការរីកចំរើនយ៉ាងណា?
- ទទួលបាននូវទំនប់ចិត្តពីក្រុមហ៊ុនអំពីបទដ្ឋានបច្ចេកទេសវារីអគ្គិសនី ។
- ដឹងពីការប្រែប្រួលបរិស្ថានក្នុងពេលសាងសង់ទំនប់វារីអគ្គិសនី ។
- ភាពរីកចំរើនក្រោយការសាងសង់រួច ។
- បានយល់ដឹងពីផលប៉ះពាល់បរិស្ថាន នឹងការរីកចំរើនក្នុងការអភិវឌ្ឍប្រទេសជាតិ ដោយប្រជាពលរដ្ឋមានភ្លើងប្រើពីវារីអគ្គិសនី ។
- យល់ដឹងពីការប៉ះពាល់ និងវិធានការការពារបានច្រើនក្រោយពេលសិក្ខាសាលា ។
- បានយល់ដឹងពីផលប៉ះពាល់អវិជ្ជមាននៅពេលសាងសង់អគ្គិសនី និងបាត់បង់ ជំរកត្រី ។
- យល់ដឹងពីការប៉ះពាល់បរិស្ថានផ្ទាល់ និងប្រយោលរបស់ប្រជាពលរដ្ឋ ។
- យល់ច្បាស់ពីផលប្រយោជន៍ប្រទេសជាតិ ។
- ព័ត៌មានពីវារីអគ្គិសនីកំចាយ និងបានផ្ដល់នូវមតិដើម្បីចូលរួមក្នុងការកែលំអឱ្យ បានសមស្រប
- បានបញ្ចេញសមត្ថភាព ក្នុងសិក្ខាសាលា ។

## ផ្សេងៗ

៧- ក្នុងក្រុមពិភាក្សា តើអ្នកមានពេលវេលាគ្រប់គ្រាន់ក្នុងការបញ្ចេញយោបល់ជាមួយអ្នករួមក្រុម និងអ្នកចូលរួមដទៃទៀតដែរឬទេ?

គ្រប់គ្រាន់ : ២៥នាក់ មិនគ្រប់គ្រាន់ : ០២នាក់

៨- តើអ្នកគាំទ្រគំរោងនេះ ដែរឬទេ ?

បាទ / ចាស: ២៧នាក់ (១០០ភាគរយ) ទេ : 0

# រូបថតកិច្ចប្រជុំប្រឹក្សាយោបល់ជាមួយអង្គភាពពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ខេត្តកំពត



ការប្រឹក្សាយោបល់ជាមួយលោក **ហេង ខុន្ថា** អភិបាលរង ខេត្តកំពត និងលោក **ស៊ុយ ធា** ប្រធានមន្ទីរបរិស្ថាន ខេត្ត កំពត នៅថ្ងៃទី១១/០៣/២០១០



ការប្រឹក្សាយោបល់ជាមួយលោក **សោម ទិចិត្រ** ប្រធានមន្ទីរ ឧស្សាហកម្ម រ៉ែនិងថាមពលខេត្តកំពត នៅថ្ងៃទី១១/០៣/២០១០



ការប្រឹក្សាយោបល់ជាមួយលោក **ង៉ាង ប៊ុណ្ណារដ្ឋ** ប្រធានមន្ទីរ រៀបចំនគរដែនដី រូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពត នៅថ្ងៃទី១០/០៣/២០១០



ការប្រឹក្សាយោបល់ជាមួយលោក **ម៉ុន ចាន់គង់** ប្រធានវដ្តករ ទឹក និងលោក **ខឡូ សាម៉ុន** អនុប្រធានវដ្តករទឹក ខេត្តកំពត នៅថ្ងៃទី ១០/០៣/២០១០



ការប្រឹក្សាយោបល់ជាមួយលោកស្រី **ម៉េង សុធា** អភិបាលរង ស្រុកទឹកឈូ ខេត្តកំពត, នៅថ្ងៃទី ១៥/០៧/២០១០



ការប្រឹក្សាយោបល់ជាមួយ **លោក ឈឹម សឿន** ប្រធាន អគ្គិសនី ខេត្តកំពត, នៅថ្ងៃទី ១១/០៣/២០១០

Draft

## រូបថតកិច្ចប្រជុំប្រឹក្សាយោបល់ជាមួយអន្តភាពពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងក្រុមហ៊ុន Sinohydro



ការប្រឹក្សាយោបល់ជាមួយលោក **ចាន់ ខណ្ណា** ប្រធានមន្ទីរធនធានទឹកនិងឧត្តុនិយមខេត្តកំពត.នៅថ្ងៃទី១១/០៣/២០១០



ការប្រឹក្សាយោបល់ជាមួយលោក **ឡិម ម៉ាក់ឆូរី** នាយខ័ណ្ឌរដ្ឋបាលព្រៃឈើ ខេត្តកំពត.នៅថ្ងៃទី១២/០៣/២០១០



ការប្រឹក្សាយោបល់ជាមួយលោក **យិន ភារម្យ** នាយកឧទ្យានជាតិមុនីវង្ស បូកគោ ខេត្តកំពត.នៅថ្ងៃទី ១២/០៣/២០១០



ការប្រឹក្សាយោបល់ជាមួយលោក **ថៃ សាម៉ន** នាយរងខ័ណ្ឌរដ្ឋបាលជលផល ខេត្តកំពត នៅថ្ងៃទី ១១/០៣/២០១០

Draft



ការប្រឹក្សាយោបល់ជាមួយលោក **XI Peng** នាយកទទួលបន្ទុកកិច្ចការពាណិជ្ជកម្ម និង គ្រប់គ្រងកុងត្រា ខេត្តកំពត នៅថ្ងៃទី ១២/០៣/២០១០



ការប្រឹក្សាយោបល់ជាមួយលោក **សេង អាយ** មេឃុំ ម៉ាក់ប្រាង ស្រុកទឹកឈូរ ខេត្តកំពត នៅថ្ងៃទី ២១/១០/២០១០



ការប្រឹក្សាយោបល់ជាមួយលោក ទិត ណាន់
មេឃុំកំពង់ត្រែង នៅថ្ងៃទី២៦/១០/២០១០



ការប្រឹក្សាយោបល់ជាមួយលោក គុយ យ៉ា
ជំទប់ទី១ ឃុំព្រៃឃ្មុំ នៅថ្ងៃទី២៨/១០/២០១០



ការប្រឹក្សាយោបល់ជាមួយលោក គង់ សាន់
មេឃុំព្រៃថ្នង នៅថ្ងៃទី៣០/១០/២០១០



ការប្រឹក្សាយោបល់ជាមួយលោក ចាន់ ស៊ារី
ប្រធានមណ្ឌលសុខភាព កំពង់ត្រែង
នៅថ្ងៃទី០១/១១/២០១០

Draft

**រូបថតសិក្ខាសាលាស្តីពីលទ្ធផលវាយតំលៃហេតុប៉ះពាល់បរិស្ថានលើគំរោងវារីអគ្គិសនីកំចាយ**
**នៅសណ្ឋាគារ កំពត ឌីយ៉ាម៉ង់, ក្រុងកំពត ថ្ងៃទី ២៥ ខែ មិនា ឆ្នាំ ២០១១**





សកម្មភាពចុះវត្តមានរបស់សមាជិកសិក្ខាសាលា





សន្ទរកថាបើកអង្គសិក្ខាសាលារបស់ លោក **ហេង វត្ថា**, អភិបាលរងខេត្តកំពត





សកម្មភាពកិច្ចពិភាក្សាតាមក្រុមរបស់សមាជិកសិក្ខាសាលា





សកម្មភាពធ្វើបទបង្ហាញតាមក្រុមរបស់សមាជិកសិក្ខាសាលា

Draft